ញ៉ុក . ថែម

# មហាវេស្សន្តរជាតក



កណ្ឌទី ៥

ផ្សាយឡើងវិញ "មណ្ឌលពុទ្ធកេរ្តិ៍"

រក្សាសិទ្ធិគ្រប់យ៉ាង

ព.ស ២៥៥០ គ.ស ២០០៦

# មហាវេស្សន្តរជាតក

ទី ៨

## កណ្ហកុមារបព្វ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ជូជកោបិ អច្ចុតតាបសេន កាថិតមគ្គេន យាវ ចតុរស្ស-ចោក្ខរណីតីរំ បត្វា ចិន្តេសិ អជ្ជាតិសាយណ្ហោ ឥទានិ មទ្ទី អរញ្ញតោ អាគមិស្សតិ មាតុគាមោ ហិ នាម ទានស្ស អន្តរាយករោ ហោតិ ស្វេ តស្សា អរញ្ញគតកាលេ អស្សមបទំ គន្ត្វា វេស្សន្តរំ ឧបសង្កមិត្វា ទារកេ យាចិត្វា តាយ អាគតាយ ឯវន្តេ គហេត្វា មគ្គំ បដិបជ្ជិស្សាមីតិ ។

ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ នេះនឹងដំណាល កាលជូជកព្រាហ្មណ៍ស្វះស្វែងតាមរកព្រះពោធិសត្វ ទៅដោយនូវផ្លូវដែលព្រះអច្ចុតមហាឫសីចង្អុលប្រាប់នោះ ក៏ព្រាហ្មណ៍ដើររៀងរាបដរាបដល់ស្រះបោក្ខរណី ដ៏មានមុំនោះបួន រាបទាបប្រពៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រេចហើយនៃ ទើបព្រាហ្មណ៍យកដៃស្ទឹមចង្កេះ រិះគិតថា អជ្ជាតិ-សាយណ្ហេ ឱវេលាល្ងាចណាស់ហើយហ្ន៎ ! វេលានេះ គាប់ជួនប្រជួប នឹងព្រះនាងមទ្រីមកពីព្រៃ ក៏ធម្មតាស្ត្រីតែងស្រឡាញ់កូន ហើយពុំដែលសមប្រកបនឹងស្នូមផងឡើយ តែព្រះនាងមកទាន់ហើយ នឹងធ្វើឱ្យអន្តរាយដល់ទានបារមី នៃព្រះបរមពោធិសត្វប្រាកដហោង ។ សេ្វតស្ស អរញ្ញតតកាលេ ហ៏ះ ក៏អញនឹងរលះរលាំងអ្វីមាល្បាយ ថ្ងៃនេះព្រះនាងមក ថ្ងៃស្អែកតើព្រះនាងមិនចេញទៅព្រៃស្វែងរកផ្លែឈើនោះវិញទៀតឬអ្វី បើព្រះនាងចេញផុតទៅហើយ សឹមអញទៅឯក្រោយ ចូលទៅថ្កានអាស្រមបទសំណាក់ព្រះបរមពោធិសត្វ ហើយអញនឹងក្រាបបង្គំទូលអង្វរសូមព្រះរាជបុត្រទាំងពីរ បើព្រះបរមពោធិសត្វមហាបុរសរ័ត្ន ទ្រង់ព្រះរាជទានព្រះរាជបុត្រទាំងពីរឱ្យអញហើយ អញនឹងនាំក្មេងទាំងពីររត់បំព្រាត់ចេញមក កុំបីឱ្យសម្តេចព្រះភគវតីព្រះនាងមទ្រីស្តេចមកទាន់អញឡើយ ។ អថស្សាវិទូរេ ឯកំ សានុ-បព្វតំ អារុយ្ហ ផាសុកដ្ឋានេ និបជ្ជិ ព្រាហ្មណ៍គិតនូវប្រការអម្បាលនោះហើយ ក៏ដើរសសៀរទៅតាមចំនៀរភ្នំពុំឆ្ងាយ នឹងអាស្រមបទព្រះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពោធិសត្វនោះឡើយ ហើយក្រឡេកទៅឃើញរអាងថ្មមួយ ជាថ្លុកជង្ហុកល្អ ក៏ដើរចូលទៅផ្គូផ្គងនឹងខ្នងកោងកំពក ប្រះខ្លួនដេកហើយ ក៏សរសើរថា ‹‹ឱឋាននេះ ស្រណុកក្សេមក្សាន្តអ្វីមាល្បាយម្ល៉េះ ហើយព្រាហ្មណ៍ក៏ដេកលក់ទៅហោង›› ។

តំ បន រត្តឹ បច្ចូសកាលេ មទ្ទី សុបិនំ អទ្ទស ។ បពិត្រអើយ នាកាលរាត្រីយប់នោះឯង សម្តេចព្រះភគវតីព្រះនាមមទ្រី ទ្រង់ព្រះសុបិនជាអពមង្គល យល់ដូចបុរសមួយនោះខ្មៅទាបមិនសុភាពដូចអ្នកផងទាំងឡាយ ហើយបុរសនោះស្លៀកសំពត់ជ្រលក់ទឹកអម្ពូត់ត្រឹមចង្កេះ សៀតផ្កាប្រាលរន្ទា នៅឮដ៏ត្រចៀកទាំងសងខាង វារត់អំភ្លាងមកខាងបរមសាលា ដ៏មានដៃកាន់នីទៅនូវគ្រឿងអាវុធថ្លា ស្រែកគំរាមថា ‹‹នាងមទ្រីនៅទេហ៎ា នាងមទ្រីនៅឬទេ?›› ហើយវារត់ចូលទៅក្នុងបរមសាលា វាភើចកន្ទ្រាក់នូវសំណុំព្រះកេសាជដាមណ្ឌល នៃព្រះនាងមទ្រីឱ្យប្រះដួលផ្ងារទៅលើក្រឡាមហាប្រឹថពី ហើយវាឆ្កៀលព្រះនេត្រទាំងពីរ កាត់នូវដើមព្រះអង្សាទាំងសងខាង ហើយវារៀលវះពន្លះពុះទ្រូង រូងយកថ្លើមបេះដូងនាំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ចេញទៅ ដ៏មានព្រះលោហិតនោះ ហូរស្រោចស្រពសព្វអស់ព្រះអង្គ។ **សា មទ្ទី បពុជ្ឈិត្វា ភីតតសិតា** បពិត្រអើយ រីសម្តេចព្រះភគវតីព្រះនាងមទ្រីតើនឡើងអំពីក្រឡាបន្ទំក៏មានព្រះទ័យនោះ ភិតភ័យញាប់ញ័រចំប្រប់អស់អង្គ ទ្រង់ពិចារណាថា ‹‹ឱសប្តិនេះ វាអាស្រូវអ្វីមាល្បាយអេះ អញមិនដែលយល់សប្តិដូច្នេះសោះ បើដោយនិមិត្តសប្តិនេះ នឹងមានអពមង្គលពុំជា ឬមួយមានសិរីសួស្តីល្អទេ›› ។ ក៏ឥឡូវនេះអ្នកណានឹងចេះទាយសប្តិអញនេះ ដូចអញនៅនាជេតុត្តរនគរនោយរ៉ាអញនឹងឱ្យកវីបណ្ឌិតព្រាហ្មណ៍ព្រឹទ្ធហោរា មកជុំនុំពិចារណាទាយសប្តិនេះឱ្យអញ ឥឡូវនេះអញនៅនាព្រៃភ្នំទុគ៌មមិតរាយឆ្ងាយម្លេះ តើអញនឹងធ្វើដូចម្តេច? លុះព្រះនាងរំពឹងគិតដូច្នេះហើយ ទ្រង់ពិចារណាថា ‹‹ទេនឹងរកអ្នកចេះទាយសប្តិកំណាចនេះ ឱ្យស្មើនឹងព្រះបាទស្រីវេស្សន្តរបរមបពិត្រ ដ៏ជាក្រឡាគម្លែងវិសេស នៃអញនេះគ្មានឡើយ បើដូច្នេះ គួរអញទៅថ្វាយបង្គំប្រណម្យព្រះអង្គ ឱ្យទ្រង់ទាយសប្តិអញនេះ ។ ព្រះនាងទ្រង់ព្រះចិន្តានូវប្រការអម្បាលនោះហើយ ស្តេចលីលាយាត្រាចេញពីព្រះបរមសាលាទាំងរាត្រីនោះឯង លុះដល់ទ្វារព្រះបរម

Websites: WatKhemaraRatanaram.org or WatKhmers.org

សាលាហើយ ព្រះនាងពុំហ៊ានទូលដាស់ឡើយ យកតែព្រះហស្ដនោះ គោះសន្លាក់ទ្វារព្រះបរមសាលានោះកូវ ។

អថ មហាសត្តោ តំ សទ្ទំ សុត្វា កាលនោះ ព្រះបរមពោធិសត្វមហាបុរសរ័ត្ន ព្រះអង្គឮស័ព្ទព្រះនាងគោះទ្វារ ទើបត្រាស់ដណ្ដឹងទៅថា «កោ ឯសោ នរណាហ្នឹង? មកគោះទ្វារព្រះអាស្រមបទកុដិទាំងរាត្រីថ្នារនេះ យល់ពុំជួកាលដូចសព្វដង» ។ ទើបព្រះនាងក្រាបបង្គំទូលស្នងព្រះរាជឱង្ការ ពីខាងក្រៅថា «អហំ ទេវ មទ្ទី បពិត្រព្រះសម្មតិទេព អញខ្ញុំឈ្មោះមទ្រី ជាខ្ញុំស្រីព្រះអង្គ» ។ សម្ដេចព្រះមហាសត្វទ្រង់ស្ដាប់ជាក់ជាព្រះមទ្រីហើយ ព្រះអង្គមានព្រះទ័យពុំស្រណុកឡើយ ទើបមានព្រះបន្ទូលទៅកាន់ព្រះនាងមទ្រីថា «មទ្រីនាងអើយ នាដំណើរនាងមកកាន់អញនេះ នោះមានបំណងប៉ុនប៉ងនឹងទំលាយក្រឹត្យវត្ត ប្រណិប័តន៍អញនេះ ឱ្យអន្តរាយមិនទេឡើយ ។ យើងបានស្រដីប្ដេជ្ញានឹងគ្នាហើយតើ ពីកាលយើងទើបមកដល់ តម្កល់ជាអ្នកបួសនេះ ថាបើវេលាពុំជួកាល កុំអាលនាងមកកាន់អញឡើយ ក៏ឥឡូវនេះ ហេតុអ្វីឡើយក៏នាងមកកាន់អញ

Websites: WatKhemaraRatanaram.org or WatKhmers.org

នាវេលាពុំជួកាលដូច្នេះរឹងហឺះ ?»។

សម្តេចព្រះនាងមទ្រីក្សត្រីឧត្តមប្រណម្យទូលថា «បពិត្រព្រះសម្មតិទេពមហារាជអើយ នាព្រះបន្ទូលព្រះអង្គគាប់ពិត ប៉ុន្តែសូមទ្រង់ព្រះមេត្តាស្តាប់អញ្ញខ្ញុំសិន នឹងក្រាបបង្គំទូលឱ្យសព្វព្រះហឫទ័យ នាអញ្ញខ្ញុំមកនេះ ហៅឆ្លងនឹងព្រះរាជអាជ្ញាព្រះបាទបរមបពិត្រហើយ គឺមោះអញ្ញខ្ញុំមកនេះ ពុំប្រាថ្នាដោយនូវវិស័យលោកធម៌នោះឡើយ នាអញ្ញខ្ញុំមកនេះ ត្បិតអញ្ញខ្ញុំយល់សប្តិអាក្រក់ សូមទ្រង់ព្រះករុណាទ្រង់ពិចារណាសប្តិនេះឱ្យទាន» ។ ព្រះបាទស្រីវេស្សន្តរបរមបពិត្រស្តេចស្តាប់ព្រះបន្ទូលសម្តេចព្រះនាងមទ្រីក្សត្រី ដោយនូវដំណើរដូច្នោះក្តី ព្រះអង្គមានព្រះហឫទ័យនោះក្សេមក្សាន្ត មានព្រះបន្ទូលថា «មទ្រីអើយ ថាបើដូច្នោះ ចូរនាងថ្លែងសំដែងប្រាប់អញអំពីខាងក្រៅនោះមក អញពិចារណាសប្តិឱ្យនាងហោង» ។ ទើបសម្តេចព្រះនាងមទ្រី ថ្លែងសំដែងសប្តិ ដូចព្រះនាងបានយល់នោះសព្វគ្រប់ប្រការ ។

កាលនោះ ព្រះមហាក្សត្រទ្រង់ព្រះចិន្តាពិចារណា ដោយប្រាជ្ញាទិព្វឈ្វេងយល់ពុំកំបាំងដល់តិចឡើយ ។ ស្វេ នៅថ្ងៃស្អែកនេះ

ឯងហើយ នឹងមានស្មូមយាចកមួយ មកសូមកូនអញទាំងពីរ ជាទានបារមីហៅបុត្តបរិច្ចាគនឹងបានពេញបរិបូណ៌ នាកាលថ្ងៃស្អែកនេះ ។ បើដូច្នេះអញនឹងប្រាប់នាងមទ្រីដោយនូវពិតឯណាក៏បាន ត្បិតជាអ្នកសោកស្តាយ ស្រឡាញ់កូនទាំងពីរនោះណាស់ គួរអញប្រាប់បង្វែងវិញ ។ ទើបព្រះអង្គមានព្រះបន្ទូលថា «ហៃមទ្រីក្សត្រីប្រសើរអើយ ចូរកុំថប់បារម្ភនឹងសប្តិនេះឡើយ រីនាងយល់សប្តិអាក្រក់នោះ ត្បិតនាងធ្លាប់នៅនានគរបវររាជដ្ឋាននាយនោះ រែងផ្ទំលើកម្រាលពូកព្រៃព្រំចៀមចំបន្ទំក្រោមស្វេតច្ឆ័ត្រពិចិត្រប្រសើរ ឥឡូវនេះ នាងមកដេកលើកម្រាលស្លឹកឈើ នៅនាមហាប្រឹថពីធូលីដីខ្សាច់ ។ មួយសោតនាងធ្លាប់បរិភោគនូវភោជនាហារ សឹងតែភោជ្ជសាលី ប្រសើរទន់ពិសា ប្រដាប់ទុកលើសុពណ៌ភាជន៍មាស មានឱជារសពិសាត្រកាលផ្សេង ៗ ឥឡូវនេះ នាងបរិភោគតែផ្លែឈើទុំ ច្រឡំនូវទឹកឃ្មុំឥតមេនេះ ហេតុនេះបណ្តាលឱ្យទៅជាររើយរវាយ យល់សប្តិអាក្រក់គឺមោះ រីសប្តិនាងនេះល្អជាទេ កុំនាងបារម្ភឡើយ ចូរនាងទៅកាន់អាស្រមវិញចុះ ខ្លាចកូនទាំងពីរភ្ញាក់ឡើងយំរកម្តាយ» ។ ព្រះពោធិសត្វល្បួង

Websites: WatKhemaraRatanaram.org or WatKhmers.org

លោមនាងដូច្នោះហើយ ទើបឱ្យដំណើរនាងត្រឡប់ទៅវិញហោង ។

បពិត្រអើយ លុះព្រឹកព្រហាមតាមអរុណោទ័យថ្ងៃរះឡើង ក្លូវ សម្ដេចព្រះនាងមទ្រីទេវី ប្រដាប់នូវអំពើទាំងពួងដ៏គួរធ្វើជាដើម គឺ ដងទឹកសោយ ទឹកស្ងួន់ ទឹកលាងព្រះបាទ ទឹកស្រង់ ថ្វាយព្រះពោធិសត្វហើយ ព្រះនាងថ្នមព្រះរាជបុត្រទាំងពីរ បីឡើងតម្កើង តម្កល់ដល់លើព្រះឱរា ហើយបន្ទូលថា ‹‹ម្នាលកូនសម្លាញ់ម្ដាយអើយ នាយប់មិញ ម្ដាយយល់សប្តិអាក្រក់ពេក កូនស្ងួនទាំងពីរម្ដាយអើយ កុំបីបាប្រហែសខ្លួនដើរទៅលេងទីទៃ ៗ ឡើយ›› ។ ព្រះនាងឱ្យដំបូន្មានព្រះរាជបុត្រម្ល៉ោះហើយ ក៏ទ្រង់ពយកទៅថ្វាយព្រះមហាក្សត្រ ក្រាបបង្គំទូលថា ‹‹បពិត្រព្រះសម្មតិទេព អម្ចាស់ខ្ញុំអើយ កុំបីព្រះអង្គប្រហែសព្រះរាជបុត្រទាំងពីរ កុំឱ្យទៅលេងឆ្ងាយនឹងព្រះអង្គឡើយ›› ។ សម្ដេចព្រះនាងមទ្រីក្សត្រីឧត្ដម ទ្រង់បង្វែរព្រះរាជបុត្រទាំងពីរថ្វាយព្រះមហាក្សត្រដូច្នោះហើយ ទើបព្រះនាងប្រដាប់នូវកញ្ជើ សង្រែក ដងវែក ជ្រនីក ទំពក់ ពុំស្រណុកក្នុងព្រះរាជហឫទ័យ ខ្សឹកខ្សួលអួលអាក់ក្នុងព្រះឱរា ។ ទ្រង់ព្រះកន្សែង ហូរទឹកព្រះនេត្រា

Websites: WatKhemaraRatanaram.org or WatKhmers.org

សស្រាក់ ពព្រាក់អំភ្លាង ព្រះនាងខំទប់យាងព្រះបាទ ចូលទៅក្នុងព្រៃ អាស្រ័យប្រយោជន៍ នូវបេះផ្លែឈើ ជីកមើមដំឡូងផងទាំងឡាយ ឰដ៏កាលនោះឯង ។

ផុជកោបិ ឥជាជិ មទ្ទី អរញ្ញ គតា ភវិស្សតីតិ ។ ហៃសាធុសប្បុរសផងទាំងឡាយអើយ រីឯជូជកព្រាហ្មណ៍ ភ្ញាក់ឡើងពីដេកក្រឡេកមើលទៅគិតថា ព្រឹកហើយហ្ន ថ្ងៃនេះសមសម្តេចព្រះនាងមទ្រី សម្តេចលីលាទៅព្រៃមិនទេឡើយ ហើយគួរអញចូលទៅម្ទីម្នាថ្វាយបង្គំប្រណម្យព្រះបាទស្រីវេស្សន្តរក៏បានអេះ ព្រាហ្មណ៍គិតដូច្នោះហើយ ចុះកកេបកកាបដោះឡើង ប្រវាបានឈើច្រត់ នូវថង់ស្បៀងស្ពាយឆៀងដើរសសៀរចុះមកពីលើទីជំរាលភ្នំនោះ ដើរទៅដោយនូវផ្លូវចង្អៀតចុះតែជើងអ្នកមួយ ដើរទន្ទបលលបឆ្ពោះមុខទៅលំនៅអាស្រមបទនោះហោង ។

មហាសត្តោបិ បណ្ណសាលតោ និក្ខមិត្វា ចាសា-ណាផលកោ សុវណ្ណបដិមា វិយ និសីទិត្វា ចិន្តេសិ ។ កាលនោះ ពង្សពូជព្រះពោធិសត្វ បានទ្រង់ព្រះពិចារណាសប្តិសម្តេចមទ្រីអំពី

Websites: WatKhemaraRatanaram.org or WatKhmers.org

យប់ ទ្រង់សព្វព្រះរាជហឫទ័យ ថានឹងមានស្នូម មកសូមព្រះរាជបុត្រទាំងពីរដូច្នោះមិញ ព្រះអង្គស្តេចចេញពីបណ្ណសាលា វេលាព្រឹកព្រហាម មកគង់រង់ចាំលើដំបារថ្ម មានព្រះអង្គល្អបីដូចព្រះរូបបដិមាមាស គិតដ៏ជាងទងបោះថ្មីល្អប្រសើរ ព្រះអង្គទន្ទឹងទតមើលផ្លូវជូជកព្រាហ្មណ៍ថា «កាលឯណាអេះ ស្នូមនឹងចូលមកសុំអញ» ។ លោកឧបមាថា ព្រះរាជហឫទ័យព្រះអង្គគង់រង់ចាំស្នូមនោះដូចបុគ្គលប្រមឹកស្រា លុះព្រះហាមទ្បើង ប្រើប្រពន្ធឱ្យទៅទិញស្រាឯផ្សារ ខ្លួនឯងអង្គុយចាំនៅមាត់ទ្វារ តែងនឹងទន្ទឹងថា មកឆាប់ ៗ រ៉ា អញនឹងអាលផឹក ។ ព្រះហឫទ័យព្រះអង្គអាល័យ ចង់ឱ្យទានមិនមានរួញរា ក៏មានឧបមាបីដូច្នោះហោង ។ បុត្តាបិស្ស ចាឧម្ហេ គីឡន្តិ កាលនោះសម្តេចព្រះរាជបុត្រទាំងពីរ លេងពុំឆ្ងាយនឹងព្រះបាទព្រះអង្គឡើយ ព្រះពោធិសត្វមហាបុរសរ័ត្នបពិត្រព្រះអង្គទតទៅនាផ្លូវឆ្ងាយបន្តិចទៅក្លូវ យល់ជូជកព្រាហ្មណ៍ ដើរតម្រង់មករក ព្រះអង្គមានព្រះហឫទ័យត្រេកអរក្រៃ ហាក់ដូចទានដែលបានកប់ទុកមក ៧ ខែហើយ ទើបព្រះអង្គមានព្រះបន្ទូលថា «ឯហិ វត ភោ ព្រាហ្មណ» ហៃចៅព្រាហ្មណ៍

Websites: WatKhemaraRatanaram.org or WatKhmers.org

អើយ ចូរថៅមកអាយព៉ា អញទន្ទឹងចាំថៅទេតើ ស្តេចមានបន្ទូលនឹងព្រាហ្មណ៍ដូច្នោះហើយ រឹងត្រេកអរក្នុងព្រះរាជហឫទ័យ បន្ទូលហៅជាលីកុមារ ដោយនូវបាទគាថាដូច្នេះ ៖

ឧដ្ឋេហិ ជាលិ បតិដ្ឋ    ចោរាណំ វិយ ទិស្សតិ
ព្រាហ្មណំ វិយ បស្សាមិ    ឧន្ទិយោ មាភិភីររេតិ ។

តាត ហៃថៅជាលីបុត្រច្បងពិសីទន្ទុកពន្លក ស្ងួនសំឡាញ់ឱពុកអើយ ឧដ្ឋេហិ ចូរបាដោះឡើងមកឈរផ្ទោះមុខឪពុកបន្តិច ចោរាណំ វិយ ទិស្សតិ ឪពុកស្រណោះ ហាក់ដូចឪពុកនៅនាជេតុត្តរនគរ តែងឱ្យទានដល់ស្មូមយាចកផងទាំងឡាយ ចូរបារមិលមើលទៅមុខ ហាក់ដូចមានព្រាហ្មណ៍ដើរចូលមក ឧន្ទិយោ មាភិភីររេ ឥឡូវនេះ ឪពុកមានអំណរផ្សព្វផ្សាយ ដូចជាកាលនោះហោង ។

ឯថៅជាលី ស្តាប់ព្រះបន្ទូលដូច្នោះហើយ ទើបប្រណម្យក្រាបបង្គំទូលថា ៖

អហំបិ តាត បស្សាមិ    យោ សោ ព្រហ្មារ ទិស្សតិ
អត្ថិកោ វិយ អាយាតិ    អតិថី នោ ភវិស្សតីតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រព្រះវររាជបិតា ខ្ញុំព្រះអង្គក៏បានឃើញដែរ ឯបុរសនោះ យល់ប្រាកដដូចជាព្រាហ្មណ៍ បពិត្រព្រះអង្គ ព្រាហ្មណ៍នេះមកជាភ្ញៀវនៃយើង គឺមោះមានបើប្រាថ្នាអ្វីមួយមិនទេឡើយ ។ ថៅជាលីកុមារក្រាបទូលព្រះវរបិតាដូច្នោះហើយ ក៏ម្នីម្នាដោះឡើងរត់ទៅទទួលអស់គ្រឿងបរិក្ខារអំពីជូជកព្រាហ្មណ៍ ។ កាលនោះ ព្រាហ្មណ៍រមិលមើលមកយល់ព្រះរាជបុត្រ គិតថាអេះនេះឯងហើយ ព្រះរាជបុត្រព្រះបាទស្រីវេស្សន្តរ ឈ្មោះថៅជាលីកុមារ អញសង្ខាតមកពីនាយផ្លាក់អាយ ប៉ុនប៉ងនឹងសូមព្រះរាជកុមារនេះ ទៅធ្វើជាខ្ញុំនាងអមិត្តតាបនា ជាភរិយានៃអញ បើដូច្នេះអញនឹងស្រដីពាក្យពីរោះផងឯណាក៏បាន ចាប់ដើមពីថ្ងៃនេះទៅ អញនឹងស្រដីនូវពាក្យរបឹងរឹងរូសទើបកុមារនេះខ្លាច ។ *អបេហិ អបេហីតិ អច្ឆរំ បហិ* ទើបជូជកព្រាហ្មណ៍ផ្ទាត់ក្រចកប្រេស ៗ ថា ‹‹ក្មេងតូចកំណាចដោះឡើងជៀសចេញឱ្យឆាប់ បើខំដំងើចនៅនេះ មុខជាត្រូវនឹងឈើច្រតរំពាត់ឫស្សីឥឡូវនេះឯង›› ។ *កុមារោ អបគន្ត្វា* ថៅជាលីកុមារស្តាប់ពាក្យព្រាហ្មណ៍ហើយគិតថា ‹‹ព្រាហ្មណ៍នេះរបឹងរឹងរូសអ្វីមាល្បាយអេះ››

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រង់ទតពិចារណាអស់ប្រទ្បុងសរិលព្រាហ្មណ៍នោះទៅ ក៏ឃើញទោសចង្រៃអប្បល័ក្ខណ៍ ១៨ ប្រការ មាននៅនឹងខ្លួនព្រាហ្មណ៍ ទើបព្រាហ្មណ៍នេះរបឹងរឹងរូសណាស់ ។

ព្រាហ្មណោបិ ពោធិសត្តំ ឧបសង្កមិត្វា បដិសណ្ឋារំ ករោន្តោ អាហ ។ កាលនោះ ព្រាហ្មណ៍ចូលទៅគាល់ព្រះពោធិសត្វ ក្រាបទូលធ្វើបដិសណ្ឋារៈសំណេះសំណាល សូត្រជាបាទគាថាដូច្នេះ

កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា ច មកសា អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតីតិ ។

បពិត្រព្រះអង្គទ្រង់សីលសិក្ខា ជាមហាឫសីវិសេសប្រសើរអើយ នាព្រះករុណាមកគង់នៅកំទ្បុងព្រៃធំជ្រងំស្ងាត់ឆ្ងាយម្ល៉េះ តើជាផាសុកស្រណុកក្នុងព្រះអង្គជាសប្បាយ ឬមួយមានព្រះជម្ងឺរោគាពាធពុំស្រណុកជាទុក្ខក្នុងព្រះខន្ធសន្តាន ? បពិត្រព្រះរាជឫសីអើយ នា

Websites: WatKhemaraRatanaram.org or WatKhmers.org

អំពើចិញ្ចឹមជីវិតឱ្យរស់នៅដោយផ្លែឈើផងទាំងឡាយ នៅព្រៃអាយនេះ ញ៉ាំងមានមូលផលាហារច្រើនគ្រាន់សន្សំសោយបានឬទេ ? រីមូស សុច ស្រាំងស្រួយ ខ្វយក្អែប អាសិរពិស ពស់តូច ពស់ធំ ច្រឡំនូវពស់ដែក ពស់វែក ពស់ថ្លាសទន្សោង ពស់កន្ត្រោងភ្លើង ពស់ដីពស់ប្រមោយដំរី ថ្លាន់ភ្នំផង ញ៉ាំងមានច្រើនឬទេ ? រីម្រឹគីម្រឹគាពាឡសាហាវយង់ឃ្នងផង តើញ៉ាំងមានមកបៀតបៀនព្រះអង្គទេឬ ?

កាលនោះ ព្រះពោធិសត្វមហាបុរសរ័ត្ន ព្រះអង្គស្ដាប់ពាក្យព្រាហ្មណ៍ហើយ ទើបទ្រង់បដិសណ្ឋារៈ តបទៅជូជកព្រាហ្មណ៍ទ្រង់សូត្រជាបាទគាថាដូច្នេះ ៖

កុសលញ្ចេវ នោ ព្រហ្មេ អថោ ព្រហ្មេ អនាមយំ
អថោ ឧញ្ឆេន យាបេម អថោ មូលផលា ពហូ ។
អថោ ឌំសា ច មកសា អប្បមេវ សិរឹសបា
វនេ វាឡមិគាកិណ្ណេ ហឹសា មយ្ហំ ន វិជ្ជតិ ។
សត្ត នោ មាសេ វសតំ អរញ្ញេ ជីវិសោកិនំ

ឥទំបិ បឋមំ បស្សាមិ ព្រាហ្មណំ ទេវវណ្ណិនំ
អាទាយ វេឡុវំ ទណ្ឌំ អគ្គិហុត្តំ កមណ្ឌលុំ ។
ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ
អន្តោ បវិស ភទ្ទន្តេ ចាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ មធុកោ កាសមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ ព្រហ្មេ វរំ វរំ ។
ឥទំបិ ចានិយំ សីតំ អាភតំ គិរីគព្ភរា
តតោ បិវ មហាព្រហ្មេ សចេ ត្វំ អភិកង្ខសីតិ ។

ព្រហ្មេ ហៃថៅព្រាហ្មណ៍អើយ ពីដូចអ្នកស្រីពិរាស្រ្តគេបំបរបង់អញមកនៅនាព្រៃអាយនេះ សុខស្រណុកសប្បាយ ឥតរោគាព្យាធិឧត្បាតជម្ងឺតម្កាត់ឡើយ ។ ព្រាហ្មណ៍អើយ យើងចិញ្ចឹមជីវិតរស់នៅសព្វថ្ងៃនេះ ដោយការស្វះស្វែងរកផ្លែឈើបរិភោគ ។ ឯផ្លែឈើនោះសោត មានច្រើនក្តាត់ បរិភោគពុំចេះអស់ឡើយ ។ ព្រាហ្មណ៍អើយ រីមូស សុច ស្រាំងស្រួយ ខ្ទួយក្អែប ខ្លា រមាំង រមាស ទន្សោង គោព្រៃ ដំរី ខ្លា ពស់តូច ពស់ធំ ច្រឡំនីទៅនូវពស់ដែក ពស់

Websites: WatKhemaraRatanaram.org or WatKhmers.org

វែក ពស់ថ្លាសទន្សោង ពស់កន្ត្រោងភ្លើង អាសិរពិសអស់នោះ សឹងសាហាវមានច្រើន តែវាពុំដែលមកពាធាបៀតបៀនយើងឡើយ ។ ព្រាហ្មណ៍អើយ ប្រការមួយទៀត តាំងអំពីអ្នកស្រីពិរាស្ត្រ គេបំបរបង់យើងមកនៅព្រៃនេះ ជាចំនួន ៧ ខែហើយ យើងពុំដែលយល់អ្នកឯណាមួយឡើយ ទើបយល់តែចៅព្រាហ្មណ៍ឯងនេះជាប្រថម ។ ព្រាហ្មណ៍អើយ ថ្ងៃនេះយើងបានយល់តាជីត្រេកអរពេញចិត្ត គិតយល់ជាព្រាហ្មណ៍ព្រឹទ្ធ កាន់ឈើច្រត់រំពាត់ឫស្សីសម្បុរលឿងទុំ ដូចជាផ្លែល្មៅទុំ បើដោយគិតទៅ ក៏យល់ជ្រាប្រពៃក្រៃពេក ដូចកលភ្ញៀវមកដល់ថ្មីពីឋានចម្ងាយ អញ្ជើញតាជីជម្រះកាយ ញើសក្អែលលាងជើងនារោងទឹក ចូរតាជីងូតផឹកឱ្យត្រអាលក្សេមក្សាន្ត ។ ចៅព្រាហ្មណ៍អើយ ក្រែងចៅឃ្លានបាយ ផ្លែឈើផងទាំងឡាយក៏មានច្រើន គឺទន្លាប់ក្រខុប សំពារ សំពួយ ស្រេចតែចៅនឹងជ្រើសរើសយកឯណាទុំ ៗ ប្រឡាក់ទឹកឃ្មុំបរិភោគហោង ។

វត្វា ច បន មហាសត្តោ អយំ ព្រាហ្មណោ ន អគារេណោ ឥមំ មហារញ្ញំ អាគមិស្សតិ ។ ព្រះមហាពោធិសត្វមាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបន្ទូលម្ល៉ោះហើយ ព្រះអង្គគិតក្នុងព្រះហឫទ័យថា ព្រាហ្មណ៍នេះសង្ខាតឱហាតលះបង់ស្រុក រុកព្រៃពានភ្នំក្រំថ្ម មកដល់ព្រៃធំនេះប្រយោជន៍អ្វី អញនឹងដណ្តឹងដំណើរអាការនៃព្រាហ្មណ៍នេះ ទើបមានព្រះបន្ទូលជាបាទគាថាដូច្នេះ ៖

អថ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា
អនុប្បត្តោសិ ព្រហារញ្ញំ តំ មេ អក្ខាហិ បុច្ឆិតោតិ ។

ហៃព្រាហ្មណ៍អើយ អញនឹងដណ្តឹងប្រស្នែងហាៈ នាប្រស្នែងលះបង់ស្រុករុកព្រៃពានភ្នំក្រំថ្មមកដល់អាយ តើដោយនូវហេតុដូចម្តេច ? អញចង់ដឹងប្រស្នែងណាស់ ចូរប្រស្នែងថ្លែងប្រាប់ ដោយនូវពាក្យពិតត្រង់មើល ។

ជូជកោ អាហ ជូជកព្រាហ្មណ៍ស្តាប់ព្រះបន្ទូលហើយក្រាបបង្គំទូលជាបាទគាថាដូច្នេះ ៖

យថា វារិវហោ បូរោ សព្វកាលំ ន ខីយតិ
ឯវន្តំ យាចិតាគញ្ឆឹ បុត្តេ មេ ទេហិ យាចិតោតិ ។

បពិត្រព្រះមហារាជឫសីអើយ សុំទ្រង់ព្រះមេត្តាប្រោស ខ្ញុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គនឹងក្រាបទូលឱ្យសព្វព្រះរាជហឫទ័យ ។ នាខ្ញុំព្រះអង្គនេះ ជាព្រាហ្មណ៍ចាស់ឥតកំឡាំង មិនគប្បីបើនឹងយាត្រាមកកាន់ផ្លូវឆ្ងាយម្ល៉េះទេ តែខ្ញុំព្រះអង្គឮគេថា ព្រះរាជហឫទ័យថ្លៃវិសេសត្រសុំត្រសាយតែងទ្រង់អំណោយទានដល់ស្មូមយាចកជាប្រក្រតី ឮល្បីថាអស្ចារ្យទូទ័រដល់នគរកលិង្គរាស្ត្រនាយ ព្រះរាជហឫទ័យថ្លៃវិសេសដែលទ្រង់ព្រះរាជសទ្ធានោះ ពុំមានឆ្អែតឆ្អន់ដល់តិចឡើយ បីដូចអំបូរមេទឹកស្ទឹង ៥ សឹងពេញព្រៀបមាត់ច្រាំង ពុំដែលហែងហួតស្ងួតឡើយ ទោះយោបីមនុស្សសព្វសត្វម្រឹគបក្សីផង ដងនូវក្អមថ្នមនូវភាជន៍ បាននូវក្បង់ដៃដងដាក់ក្រឡពិន្ទងបាចសាច ឬងូតផឹកយ៉ាងណាក្តី នឹងស្ងួតជ្រួតជ្រាបដាច់ទឹកយល់ដល់ដីខ្សាច់នោះ ឥតអង្គឹមានឡើយ ។ រីព្រះរាជហឫទ័យប្រពៃ ក៏ពុំមានឆ្អែតឆ្អន់នឹងយាចកនោះ ក៏មានគួរនាបីដូច្នោះដែរ ។ បពិត្រព្រះមហារាជឫសីអើយ ខ្ញុំព្រះអង្គជាព្រាហ្មណ៍ចាស់ឥតកម្លាំង ពឹងតែឈើច្រត់ខំដើររុករានពានភ្នំក្រំថ្ម ប្រទះនឹងមហឹង្សា ខ្លារមាំង រមាស ទន្សោង គោព្រៃ ភិតភ័យខំរត់ពពឹមពពាម រួចមកដល់យល់ព្រះអង្គទ្រង់ធម៌សប្បុរសនេះ ប្រាថ្នាសង្វាតមកសូមព្រះរាជបុត្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទាំងពីរ សូមព្រះមហារាជព្រះរាជទានឱ្យខ្ញុំព្រះអង្គហោង ។

តំ សុត្វា មហាសត្តោ សោមនស្សប្បត្តោ ហុត្វា

កាលនោះ ព្រះមហាសត្វស្ដាប់ពាក្យព្រាហ្មណ៍ហើយ មានព្រះហឫទ័យត្រេកអរមហិមា បីដូចបុរសមួយតាំងពីតូចដល់ធំ ពុំដែលមានមាសដល់បីពៃ មានកាលមួយថ្ងៃ មានបុរសម្នាក់យកមាស ១ ពាន់តម្លឹង ច្រកនឹងថង់ផ្ទង់ដាក់នឹងដៃបុរសនោះ បុរសនោះមានចិត្តត្រេកអរដូចម្ដេចមិញ ក៏ព្រះអង្គមានព្រះរាជហឫទ័យត្រេកអរសាទរ មានឧបមាបីដូច្នោះហោង ។ ទើបព្រះអង្គនឹងធ្វើឱ្យកក្រើកអំពើក នូវព្រៃភ្នំវង្កតបពិតដ៏មហិមា ក៏មានព្រះបន្ទូលនូវបាទព្រះគាថាដូច្នេះ ៖

ទទាមិ ន វិកម្បាមិ ឥស្សរោ នយ ព្រហ្មណា
ចាតោ តតា រាជបុត្តី សាយំ ឧញ្ញាតោ ឯហិតិ
ឯករត្តឹ វសិត្វាន ចាតោ កច្ឆសិ ព្រាហ្មណា ។
តស្សា ឆាតោ ឧបក្ខាតេ អថ ទេ មាលវិទេ
ឯករត្តឹ វសិត្វាន ចាតោ កច្ឆសិ ព្រាហ្មណា ។
នានាបុប្ផេហិ សញ្ឆន្នេ នានាគន្ធេហិ ភូសិតេ

Websites: WatKhemaraRatanaram.org or WatKhmers.org

នានាមូលផលាគិណ្ណេ   តច្ឆស្សាទាយ ព្រាហ្មណាតិ ។

ហៃព្រាហ្មណ៍អើយ រីកូនអញទាំងពីរនេះ អញលើកឱ្យប្រស្ពៃង ចិត្តអញនឹងមានញាប់ញ័រ ទៅដោយនូវក្តីកំណាញ់នោះគ្មានឡើយ អញឱ្យដោយនូវចិត្តសទ្ធាស្មោះ ។ ព្រាហ្មណ៍អើយ ពីថ្ងៃនេះទៅ ចៅជាឥស្សរកំពូល នៃកូនអញទាំងពីរនេះ តែនាងមទ្រីក្សត្រីប្រសើរ នាងទៅព្រៃពីព្រឹកព្រហាមពុំទាន់មកដល់ អញចង់ឃាត់ចៅឱ្យនៅខានសម្រាន្តអាយ តែក្នុងរាត្រីនេះសិន រង់ចាំនាងមទ្រីមក នាងនឹងយកទៅផ្ងូតទឹកកក់ជម្រះ ហើយនាងនឹងបេះភ្ញីផ្កាផ្សេង ៗ មកក្រងចងបំពាក់ ហើយនឹងយកគន្ធពិដោរផ្សេង ៗ មកលាបស្រឡាបអស់អង្គ ហើយនាងនឹងផ្ទង់ផ្លែឈើមានរសពិសាផ្សេង ៗ ឱ្យក្មេងទាំងពីរបរិភោគ ឱ្យឆ្អែតស្កប់ស្កល់ ។ ព្រាហ្មណ៍អើយ ដល់ព្រហាមឡើងសឹមចៅនាំយកកូនអញទៅហោង ។

ជូជកោ អាហ ជូជកព្រាហ្មណ៍ ស្តាប់ព្រះបន្ទូលព្រះមហាក្សត្រហើយ ពុំចូលចិត្ត ខ្លាចក្រែងព្រះនាងមទ្រី ពុំទ្រង់ព្រះរាជសទ្ធា ទើបក្រាបបង្គំទូលជាបាទគាថាដូច្នេះ ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

ន វាសមភិរោចាមិ កមដំ មយ្ហំបិ រុច្ចតិ
អន្តរាយោបិ មេ អស្ស កច្ឆញ្ញេវ រថេសភ ។
ន ហោតា យាចយោគី ជំ អន្តរាយស្ស ការិយា
ឥត្ថិកា មន្តំ ជានន្តិ សព្វំ កណ្ហាន្តិ វាមតោ ។
សទ្ធាយ ទានំ ទទតោ មា សមទក្ខិ មាតរំ
អន្តរាយំបិ សា កយិរា កច្ឆញ្ញេវ រថេសភ ។
អាមន្តយស្សុ តេ បុត្តេ មា តេ មាតរមទ្ទសុំ
សទ្ធាយ ទានំ ទទតោ ឯវំ បុញ្ញំ បវឌ្ឍតិ ។
អាមន្តយស្សុ តេ បុត្តេ មា តេ មាតរមទ្ទសុំ
មាទិសស្ស ធនំ ទត្វា រាជ សគ្គំ គមិស្សសីតិ ។

បពិត្រក្សត្រថ្លៃប្រសើរអើយ ខ្ញុំព្រះអង្គពុំចូលចិត្តចង់ខានសម្រាន្តនៅអាយដូចព្រះបន្ទូលឡើយ ហើយចាំព្រះនាងនោះយល់ពុំសម ខ្ញុំព្រះអង្គនឹងក្រាបបង្គំលាទៅក្នុងកាលឥឡូវនេះឯង ខ្លាចក្រែងសម្តេចព្រះនាងមទ្រីមានព្រះហឫទ័យពុំចង់ឱ្យទាន ព្រោះធម្មតាស្ត្រី

Websites: WatKhemaraRatanaram.org or WatKhmers.org

តែងនាំឱ្យអន្តរាយដល់ទានបារមីរបស់បុរស **ឥត្ថិយោ** ធម្មតាស្ត្រីក្នុងលោកនេះ តែងមានមាយាក្លិកក្លក់ គិតតែបម្រុងដាក់ទុកក្នុងវដ្តសង្សារ កម្រនឹងត្រអាលលើកយកបុត្រាបុត្រីឱ្យជាទាន ឥឡូវ សូមព្រះអង្គលើកព្រះរាជបុត្រទាំងពីរឱ្យជាទានខ្ញុំព្រះអង្គ ដោយនូវព្រះរាជសទ្ធា កុំបីរារង់ឱ្យព្រះរាជកុមារបានយល់ព្រះមាតាឡើយ ថាបើព្រះអង្គទុកឱ្យបានយល់ព្រះមាតាហើយ នឹងធ្វើឱ្យអន្តរាយដល់ទានព្រះអង្គជាពុំខាន ។ បពិត្រក្សត្រថ្លៃប្រសើរអើយ សូមព្រះអង្គមានព្រះបន្ទូលហៅព្រះរាជបុត្រទាំងពីរ ឱ្យវិលមកឆាប់ ៗ កុំឱ្យទាន់បានយល់សម្តេចព្រះមាតាឡើយ ។ បពិត្រព្រះរាជឫសីប្រសើរអើយ ព្រះអង្គលើកព្រះរាជបុត្រទាំងពីរឱ្យជាទាន ទុកជាទ្រព្យដ៏ប្រសើរដល់ខ្ញុំព្រះអង្គនេះ កាលណាព្រះអង្គសោយព្រះវិលាល័យក្ស័យព្រះជន្មពីជាតិនេះហើយ ព្រះអង្គនឹងទៅសោយសម្បត្តិ ឋិតនៅឰដ៏សួគ៌ទេវលោកនាយនោះទៀតប្រាកដហោង ។

ព្រះបាទស្រីវេស្សន្តរបរមពោធិសត្វ ស្តេចស្តាប់ពាក្យព្រាហ្មណ៍ហើយ មានព្រះបន្ទូលជាបាទគាថាដូច្នេះ ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

សចេ ត្វំ និច្ឆសេ ទដ្ឋុំ មម ភរិយំ បតិព្វតំ
អយ្យកស្សបិមេ ទេហិ ជាលឹ កណ្ហាជិនំ ចុភោ ។
ឥមេ កុមារេ ទិស្វាន មញ្ជុកេ បិយភាណិនេ
បតីតោ សុមនោ វិត្តោ ពហុំ ទស្សតិ តេ ធនន្តិ ។

ហៃថៅព្រាហ្មណ៍អើយ ទោះយោបីប្រស្វែងមិនចង់ខានសម្រាន្តនៅអាយ ឱ្យកូនទាំងពីរបានយល់នាងមទ្រី ជាស្រីមានវត្តប្រណិប័តន៍ដ៏ប្រសើរជាភរិយានៃអញទេ ត្បិតខ្លាចមានអន្តរាយដល់ថៅ ។ ម្នាលថៅព្រាហ្មណ៍អើយ អញសូមផ្ដាំថៅ កុំបីនាំក្មេងទាំងពីរ គឺថៅជាលី និងនាងក្រស្នា ទៅឯស្រុកកលិង្គរាស្ត្រនោះឡើយ ចូរប្រស្វែងនាំទៅឯជេតុត្តរនគរនាយថ្វាយព្រះបាទស្រីសញ្ជ័យ ជាព្រះអយ្យកោវិញ កាលណាព្រះអង្គបានទតព្រះនេត្រឃើញកុមារទាំងពីរនេះ ដែលចេះសំដីពីរោះ ស្រដីមុខគួរឱ្យស្រឡាញ់ សមព្រះអង្គនឹងពេញព្រះទ័យ នឹងព្រះថៅទាំងពីរពន់ពេក ព្រះអង្គនឹងទ្រង់ព្រះរាជទានទ្រព្យឱ្យថៅព្រាហ្មណ៍ឯងច្រើនជាពន្លឹកមិនខាន ។

ជូជកព្រាហ្មណ៍ស្ដាប់ព្រះបន្ទូលនៃព្រះបរមពោធិសត្វហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ទើបក្រាបបង្គំទូលតាមសេចក្តីយល់របស់ខ្លួន សូត្រជាបាទគាថាដូច្នេះ

អច្ចេនស្ស ភាយាមិ ។ រាជបុត្ត សុណោហិ មេ

រាជទណ្ឌាយ មំ ទជ្ជា ។ វិក្កីណេយ្យ ហានេយ្យ វា

ធិន្ទោ ជនញ្ច ទាសេ ច ។ តារយ្ហស្ស ព្រហ្មពន្ធុយាតិ ។

បពិត្រព្រះរាជបុត្រប្រសើរអើយ ខ្ញុំព្រះអង្គខ្លាចក្រែងព្រះបាទស្រីសញ្ជ័យដណ្តើមយកថៅជាលី និងនាងក្រស្នា របស់ខ្ញុំព្រះអង្គទៅ ហើយធ្វើទោសដាក់ព្រះរាជអាជ្ញាលក់ពិន័យ ឬសម្លាប់ខ្ញុំព្រះអង្គចោលបង់សៀត ឯមេអមិត្តតាបនាជាភរិយាសម្លាញ់របស់ខ្ញុំព្រះអង្គនឹងត្មះតិះដៀលថា ព្រាហ្មណ៍កញ្ជាស់នេះ ពុំចេះដើរទេសខូចខាតទាំងទ្រព្យធន វិនាសបាត់បង់ទាំងខ្ញុំកំដរ ។

ព្រះរាជឫសីមហាសត្វ ព្រះអង្គត្រាស់និពន្ធជាបាទគាថាដូច្នេះទៀតថា ៖

ឥមេ កុមារេ ទិស្វាន ។ មញ្ជុកេ បិយភាណិនេ

ធម្មេ ឋិតោ មហារាជា ។ សិវីនំ រដ្ឋវឌ្ឍនោ

លទ្ធា បីតិសោមនស្សំ ។ ពហុំ ទស្សតិ តេ ធនន្តិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ម្នាលចៅព្រាហ្មណ៍អើយ សម្តេចព្រះបរមជនក មហារាជបពិត្រស្តេចស្ថិតនៅក្នុងធម៌ តែងទ្រង់ចម្រុងចម្រើនដល់អ្នកស្រីពិរាស្ត្រ កាលព្រះអង្គបានទតឃើញព្រះរាជកុមារ មានសម្លេងពីរោះចេះសំដីមុខគួរឱ្យស្នេហាស្រឡាញ់ទាំងពីរនេះហើយ ព្រះអង្គនឹងទ្រង់មានព្រះរាជហឫទ័យបីតិត្រេកអរសោមនស្សជាពន្លឹក មុខជាទ្រង់ព្រះរាជទានទ្រព្យសម្បត្តិដល់ចៅព្រាហ្មណ៍ឯង ជាចំនួនច្រើនពុំខាន ។

ជូជកបានស្តាប់ព្រះបន្ទូលហើយ ក្រាបបង្គំទូលស្នងជាបាទគាថាដូច្នេះថា ៖

ឆាហន្តំបិ ករិស្សាមិ យំ មំ ត្វំ អនុសាសសិ
ធារកោវ អហំ ឆេស្សំ ព្រាហ្មណិយា បរិចារិកោតិ ។

បពិត្រព្រះរាជឫសីប្រសើរអើយ ខ្ញុំព្រះអង្គពុំអាចនឹងធ្វើតាមឱវាទដំបូន្មានរបស់ព្រះអង្គបានឡើយ ខ្ញុំព្រះអង្គត្រូវតែនាំព្រះរាជកុមារទាំងពីរ ទៅឯនគរកលិង្គរាស្ត្រ ឱ្យធ្វើជាខ្ញុំបំរើនាងព្រាហ្មណីជាភរិយានៃខ្ញុំព្រះអង្គហោង ។

តស្ស ផរុសវចនំ សុត្វា ធារកា ភីតា បិដ្ឋិបណ្ណសាលំ

Websites: WatKhemaraRatanaram.org or WatKhmers.org

គន្ធា ។ ព្រះរាជកុមារទាំងពីរ ឮព្រាហ្មណ៍ស្រដីរឹងរូសមហិមា ក៏មានព្រះទ័យភិតភ័យខ្លាចពេកពន់ប្រមាណ ទើបបបួលគ្នារលះរលាំង រត់ទៅពួន នៅខាងក្រោយបណ្ណសាលា តែនៅពុំសុខដូចកលជូជកព្រាហ្មណ៍នឹងតាមមកចាប់ ទើបនាំគ្នារត់ចេញពីក្រោយបណ្ណសាលាជាប្រញាប់ ចូលទៅពួននៅក្នុងជង្គុំព្រៃស្ងាត់ តែនៅពុំស្រណុកឡើយហាក់ដូចជូជកព្រាហ្មណ៍ទៅតាមចាប់ទៀត ។ ព្រះរាជកុមារទាំងពីរមានអាត្មានោះញាប់ញ័ររន្ធត់ ទើបរត់ពីនោះទៅទៀត លុះរត់ទៅដល់ឆ្នេរស្រះបោក្ខរណី ទើបនាំគ្នាឈរស្លៀកសំពត់អម្ពត់ គិតដ៏អ្នកក្រងនូវស្បូវភ្លាំងឱ្យខ្ជាប់ស្រេចហើយ ទើបស្ដេចដើរថយក្រោយចុះទៅក្នុងស្រះបោក្ខរណីនោះ យកស្លឹកឈូកគ្របពីលើសិរសា បបួលគ្នាសម្ងំនៅស្ងៀមហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះគាថាឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ ដោយបាទព្រះគាថាដូច្នេះ ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

តតោ កុមារា ព្យត្ថិតា សុត្វា លុទ្ទស្ស ភាសិតំ
តេន តេន បធាវិំសុ ជាលី កណ្ហាជិនា ចុភោតិ ។

ហៃភិក្ខុផងទាំងឡាយអើយ កាលនោះ ព្រះរាជបុត្រទាំងពីរ គឺជាលីនិងនាងក្រស្នា ឮពាក្យព្រាហ្មណ៍ស្រដី ឥតបីករុណាដូច្នោះ ក៏បបួលគ្នារត់ទៅពួនបាត់ស្ងាត់ហើយកូវ ព្រាហ្មណ៍ពុំស្រណុកសុខចិត្ត នឹងព្រះបរមពោធិសត្វនោះឡើយ ព្រាហ្មណ៍អត់ទ្រាំពុំបាន ក៏ស្រដីត្មះតិះដៀលព្រះអង្គថា ភោ វេស្សន្តរ បពិត្រព្រះវេស្សន្តរអើយ ដើមឡើយឮល្បីល្បាញថាជាអ្នកមានចិត្តសទ្ធា តែងនឹងប្រាថ្នាសន្សំបន្សំព្រះបារមី យកព្រះរាជបុត្រាបុត្រីទាំងពីរជាទានខ្ញុំតាជីហើយ លុះឮថាខ្ញុំតាជីពុំព្រមនាំព្រះរាជកុមារទាំងពីរ ទៅឯជេតុត្តរនគរដូចព្រះបន្ទូល ហើយឮថាខ្ញុំតាជីនឹងនាំទៅលំនៅខ្ញុំតាជីឯកលិង្គរាស្ត្រ ឱ្យទៅនៅបម្រើនាងអមិត្តតាបនាដូច្នោះកូវ ក៏ខ្វៃប្រែឱ្យកន្ទុយព្រះនេត្រព្រះរាជបុត្រទាំងពីរមិញឱ្យរត់បាត់អស់ទៅ ហើយគង់នៅស្ងៀមធ្វើជាមិនដឹងវិញ បពិត្រព្រះបាទស្រីវេស្សន្តរអើយ ខ្ញុំតាជីស្រាល់ជ្រើសរើសរក ព្រះមហាក្សត្រឯណាមួយនៅនាលោកិយនេះ ចេះស្រដីភូតភរស្មើនឹងព្រះអង្គនេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

គ្មានឡើយ ។

តំ សុត្វា មហាសត្តោបិ កម្បិតោ ហុត្វា ព្រះមហាក្សត្រ ទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ៍ស្រដីហើយ ព្រះអង្គមានព្រះហឫទ័យពុំស្រណុកក្រើករន្ធត់អត់ពុំបាន ទ្រង់មានព្រះចិន្ដាថា «ឱកូនអញទាំងពីរ ច្បាស់ជារត់ទៅពួនអស់ហើយ» ទើបព្រះអង្គទ្រង់ប្រលោមលោមព្រាហ្មណ៍វិញថា «ហៃព្រាហ្មណ៍អើយ កុំប្រស្នែងបារម្ភនឹងក្មេងទាំងពីរនោះឡើយ អញនឹងនាំយកមកឱ្យប្រស្នែងក្នុងកាលឥឡូវនេះឯង» ។ ទើបព្រះអង្គចេញទៅឯក្រោយព្រះបរមសាលា ទ្រង់រកមើលពុំឃើញឡើយ ទ្រង់យល់តែគន្លងស្នាមព្រះបាទ ទើបព្រះអង្គស្ដេចយាងតាមគន្លងស្នាមព្រះបាទនោះ ទៅដល់ដង្ហុំព្រៃស្ងាត់ ទ្រង់ទតឃើញតែគន្លងស្នាមព្រះបាទដើរឡើង មកអំពីស្រះនោះវិញ ទើបព្រះអង្គទ្រង់ព្រះចិន្ដាពិចារណាថា នេះជាគន្លងស្នាមជើងកូនអញ ម្ដេចក៏ឃើញតែស្នាមជើងឡើងមកវិញ តែឥតអង្គឹអ្វីមាល្បាយ សមកូនអញពួននៅក្នុងទឹកទេដឹង ។ ស្ដេចទ្រង់ជ្រាបក្នុងព្រះហឫទ័យដូច្នេះហើយ ទើបព្រះអង្គមានព្រះបន្ទូលហៅថៅជាលីជាដើម ទ្រង់សូត្រជា

Websites: WatKhemaraRatanaram.org or WatKhmers.org

បាទគាថាដូច្នេះ ៖

ឯហិ តាត បិយបុត្ត បូរេថ មម បារមឹ
ហទយំ មេភិសិញ្ចេថ ករោថ វចនំ មម
យានំ នាវា ច មេ ហោថ អចលា ភវសាគរេ
ជាតិបារំ តរិស្សាមិ សន្តារេស្សំ សទេវកន្តិ ។

តាត ហៅចៅជាលីជាបុត្រច្បងពិសី ទន្ទកពន្លកស្ងួនឪពុកអើយ បិយបុត្ត បាហោងជាកូនច្បងសំឡាញ់ព្រះជនកសព្វថ្ងៃ ឯហិ ចូរបាដោះឡើងពីទឹកនោះមកកាន់ឪពុក បូរេថ កូនអើយ ចូរបាជួយបំពេញទានបារមីរបស់ឪពុក ឱ្យបានពេញបរិបូណ៌ ក្នុងកាលឥឡូវនេះឯង ។ កូនអើយ ព្រាហ្មណ៍វាដៀលត្មះឪពុក ៗ មានចិត្តក្តៅក្រហាយនៅពុំស្រណុកឡើយ ថាបើដោះឡើងពីទឹកមកកាន់ឪពុកហើយ ស្មើបាចទឹកមួយពាន់ក្អម ផ្ទមស្រោចលើឪពុក ឱ្យត្រជាក់សប្បាយចិត្ត ។ កូនអើយ ធម្មតាកូនរែងដោយតាមពាក្យឪពុក កូនអើយឪពុកបាសព្វថ្ងៃ ស្មើសំពៅភេត្រាមាសធំចំរែ្វង សម្រាប់ចម្លងឆ្លងកាត់សមុទ្រសង្សារដាក់ដល់ត្រើយ ពោលគឺព្រះនិព្វាន ឪពុកនឹងចម្លងអស់ពពួក

Websites: WatKhemaraRatanaram.org or WatKhmers.org

សត្តនិករអមរនូវទេព្តាឥន្ទព្រហ្មមនុស្សសត្វផង ទៅដាក់ឰដ៏ឋាននិព្វាន ទាំងអស់ហោង ។

កុមារោ បិតុ តថំ សុត្វា ចៅជាលីស្តាប់ព្រះបន្ទូលសម្តេចព្រះវរបិតាហើយគិតថា ព្រាហ្មណ៍វានឹងធ្វើអញ ឱ្យបានដូចបំណងចិត្តវាហើយហាះ ថាបើអញឡើងទៅដោយនូវពាក្យព្រះជនកអញហើយ រីខ្លួនអញនេះ នឹងលុះនៅក្នុងអំណាចព្រាហ្មណ៍ប្រាកដឯងថាបើអញមិនឡើងទៅទេ យល់ល្មើសនឹងព្រះបន្ទូលនៃព្រះវរបិតាពេកណាស់ ទោះយោបីព្រាហ្មណ៍នេះវានឹងសម្លាប់អញក្តី ក៏តាមចិត្តវាចុះអញនឹងឡើងទៅថ្វាយបង្គំ កុំឱ្យព្រួយព្រះឱស្នហៅជាគម្រប់ពីរដងឡើយ សីសំ ឥហរិត្វា ចៅជាលីគិតម្ល៉ោះហើយ ក៏បើកស្លឹកឈូកអំពីព្រះសិរសាលីលាឡើងពីទឹកស្រះនោះ មកកាន់ព្រះជនកលុតជង្គង់ ឱនព្រះសិរសាក្រាបលើខ្នងព្រះបាទខាងស្តាំ ទ្រង់ព្រះកន្សែង ។ ព្រះមហាសត្វមានព្រះបន្ទូលដណ្តឹងព្រះរាជបុត្រថា ភិតជី តេ កុមារិត្ថិ ហៃចៅជាលីបុត្រច្បង ចុះនាងក្រស្នាប្អូនស្រីបាតើនៅឯណា ចូរប្រាប់ឪពុកផង ទើបចៅជាលីងើបឡើងទូលថា តាត ឥមេ សត្តា ឯាម ភយេ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឧប្បន្នេ អត្តានមេវ រក្ខន្តីតិ បពិត្រព្រះជនកអើយ ធម្មតាសត្វឯណានីមួយ តែមានភ័យហើយសឹងរត់បំពួនរក្សាខ្លួនទីទៃ ៗ ឥតដឹងដំណឹងដំនូចគ្នាឡើយ ។ ព្រះពោធិសត្វស្តាប់ពាក្យចៅជាលីហើយ ទ្រង់ព្រះចិន្តាពិចារណាថា ឱកូនអញទាំងពីរនេះ សមមានកតិកាសញ្ញាប្តេជ្ញាគ្នាហ្ន៎! ទើបព្រះអង្គមានព្រះបន្ទូលហៅនាងក្រស្នា ដោយនូវគាថាដូច្នេះ ៖

ឯហិ អម្ម បិយា ធីតា    បិយា មេ ទានបារមី
ហទយំ មេភិសិញ្ចថ    ករោថ វចនំ មម ។
យាននាវា មេ ហោថ    អចលា ភវសាគរេ
ជាតិបារំ តរិស្សាមិ    ឧទ្ធរិស្សំ សទេវកន្តិ ។

អម្ម ហៃនាងក្រស្នាពុំងាឪពុកអើយ បិយា ធីតា នាងហោងជាកូនពៅសម្លាញ់អស់ពីចិត្តឪពុក ឯហិ ចូរនាងដោះឡើងមកកាន់ឪពុករ៉ា បិយា មេ ទានបារមី ត្រង់ហៅថាទានបារមីជាទីស្រឡាញ់ពេញចិត្តរបស់ឪពុកពេក ។ ហៃក្រស្នាកូនស្រីពុំងាឪពុកអើយ នាងពុំទាន់ដឹងជាព្រាហ្មណ៍នេះ វាត្មះតិះដៀលឪពុក ៗ មានហឫទ័យក្តៅផ្សា

Websites: WatKhemaraRatanaram.org or WatKhmers.org

មហិមា ថាបើនាងឡើងមកកាន់ឪពុកហើយ ស្មើនាងយកទឹកមួយពាន់ក្អម ផ្ទមមកស្រោចស្រង់ហាឫទ័យនៃឪពុកឱ្យត្រជាក់ ។ ក្រស្នាអើយធម្មតាជាកូនវែងដោយតាមពាក្យឪពុក នាងឯងស្មើសំពៅមាសធំចិញ្ចែង ឥតក្រែងកណ្ដាលប្រវាលសមុទ្រសង្សារជ្រៅកន្លង សម្រាប់ចម្លងដាក់ដល់ត្រើយ ពោលគឺព្រះនិព្វាន ឪពុកនេះនឹងចម្លងអស់សត្តនិករ អមរន្ទេវទេព្តាឥន្ទ្រព្រហ្ម បន្សំប្រមូលទៅឰដ៏និព្វានអស់ហោង ។

*សាមិ បិតុវចនំ សុត្វា* នាងក្រស្នាស្ដាប់ព្រះបន្ទូលហើយរំពឹងជញ្ជឹងគិតតែក្នុងហាឫទ័យថា បងជាលីជាប្រុស ម្ដេចក៏មិនរឹងទទឹងនឹងព្រះរាជឱង្ការ ចុះអញជាស្រីជាប្អូនផង ម្ដេចឡើយក៏របឹងរឹងរូស ឱ្យព្រះជនកត្រាស់ហៅជាគម្រប់ពីរព្រះឱស្ឋ ទោះយោបីព្រាហ្មណ៍នេះ វាសម្លាប់អញក្ដី ក៏តាមទំនើងចិត្តវាចុះ អញនឹងឡើងទៅថ្វាយបង្គំព្រះជនកអញឥឡូវនេះ ។ ទើបនាងក្រស្នាដោះឡើងពីទឹកមកក្រាបលើខ្នងព្រះបាទខាងឆ្វេង ទ្រង់ព្រះកន្សែង ដ៏មានទឹកព្រះនេត្រហូរសស្រាក់ធ្លាក់ទៅលើខ្នងព្រះបាទាស្អាតល្អ បីដូចទឹកថ្លាធ្លាក់ទៅលើស្លឹកឈូក ។ វីព្រះបរមពោធិសត្វសោត ទប់ទល់ទឹកព្រះនេត្រពុំបាន ក៏

Websites: WatKhemaraRatanaram.org or WatKhmers.org

ទ្រង់ព្រះកន្សែងសោយសោក នឹងព្រះរាជបុត្រទាំងពីរនោះមហិមា ក្រៃពេក ទោះបីមានព្រះហឫទ័យអាសូរព្រះរាជបុត្រទាំងពីរដល់ម្ល៉េះក្តី រឹត្រង់ព្រះទ័យនឹងកង្វល់ញញូរញញា មិនចង់ឱ្យទាននោះគ្មានឡើយ ព្រះអង្គយកព្រះហស្តដ៏ទន់ល្វន់នោះ បបោសអង្អែលព្រះបង្គំនៃព្រះរាជកុមារទាំងពីរនោះ ឱ្យដោះឡើងហើយ ព្រះអង្គលួងលោមថា តាត ជាលី កឹំ ត្វំ មម ជានចិត្តភារំ ន ជានាសិ ហៃបាជាលីកូនស្ងួនសម្លាញ់ឪពុកអើយ បាមិនទាន់ដឹងទេឬ អំពីចិត្តគំនិតឪពុកតរៀងមក តែយល់ស្នូមហើយ តែងតែចង់ឱ្យទាននោះសឹងបាបានដឹងហើយ ជាលីកូនអើយ ចូរបាជួយផ្តល់អធ្យាស្រ័យរបស់ឪពុក ឱ្យលុះត្រាតែបានសម្រេចបរិបូណ៌ គោណេ អគ្ឃាបេន្តោ វិយ ព្រះអង្គមានព្រះបន្ទូលនឹងចៅជាលីដូច្នោះហើយ ទើបព្រះអង្គកាត់ថ្លៃព្រះរាជកុមារទាំងពីរនាបាននោះ ដូចឈ្មួញគោ កាត់ថ្លៃគោនាកណ្តាលផ្សារ ទើបព្រះអង្គមានព្រះបន្ទូលនឹងចៅជាលីថា តាត ជាលិ សចេ ត្វំ ភុជិស្សោ ហោតុ កា-មោ ហៃចៅជាលីបុត្រច្បងពិសីឪពុកអើយ នាខ្លួនបានេះ ឪពុកឱ្យបាជាខ្ញុំព្រាហ្មណ៍ហើយ ថាបើបានឹងចង់ឱ្យខ្លួនបាបានរួចពីខ្ញុំព្រាហ្មណ៍នេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រាហ្មស្ស និក្ខសហស្សំ ទត្វា ចូរបាយកមាសមួយពាន់តម្លឹងមកឱ្យព្រាហ្មណ៍នេះ ហើយបានឹងបានរួចចេញជាអ្នកជា ។ មួយសោត ជាលីអើយ នានាងក្រស្នាជាប្អូនស្រីពុំងាតូចនេះ កបន្ទូវលក្ខណាឆាយាល្អមកកើតនាត្រកូលអម្បូរថ្លៃ កូនអើយ ឪពុកក្រែងអ្នកឥតអម្បូរពូជពង្សទុជិន មានតែទ្រព្យយកមកចាក់ដាក់ឱ្យព្រាហ្មណ៍ យកទៅតាមចិត្តប្រាថ្នា ធ្វើជាភរិយាសេពសម្ព័ន្ធនឹងត្រកូលជាន់ទាប សន្តានជាមហាក្សត្រ នឹងបាត់បង់ច្រឡំទៅជារាស្ត្រ ។ នេះហោងជាលីកូនអើយ ឪពុកនឹងកាត់ថ្លៃនាងក្រស្នាប្អូនស្រីនៃបានេះ ដោយនូវទ្រព្យដ៏មានតម្លៃ ឱ្យលើសលន់ពន់ពេកប្រមាណច្រើនក្រៃ កុំបីឱ្យអ្នកដទៃហីនជាតិប្រមាថបាន ជាលីកូនអើយ រីអស់ប្រជានុរាស្ត្រទាសផងទាំងឡាយឯណា នឹងមានទ្រព្យដល់ម្ល៉ោះ វៀរលែងតែព្រះមហាក្សត្រាធិរាជទើបអាចមានបាន ។ ហេតុនេះជាលីអើយ បើបានឹងចង់ឱ្យនាងក្រស្នាប្អូនរួចចេញពីខ្ញុំព្រាហ្មណ៍នេះ បានជាអ្នកជា ចូរបាឱ្យមាស ១ ពាន់តម្លឹង និងខ្ញុំប្រុសខ្ញុំស្រី ដំរី ពាជី គោឧសភរាជ អស់ទ្រព្យផងនីមួយ ៗ សឹងជារយ ៗ មួយមុខ ៗ ឱ្យទៅដៃព្រាហ្មណ៍នេះ ទើបនាងក្រស្នាប្អូនស្រីបារួចចេញ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាអ្នកជាហោង ។

ឯវំ កុមារេ អត្ដាបេត្វា ព្រះបរមពោធិសត្វកាត់ថ្លៃព្រះរាជកុមារទាំងពីរយ៉ាងនេះហើយ ទើបទ្រង់ប្រលោមលួងលោមនាំទៅកាន់អាស្រមបទ ហើយទ្រង់ឈោងព្រះហស្ដចាប់យកកុណ្ឌីទឹកមក ទើបមានព្រះបន្ទូលហៅព្រាហ្មណ៍ថា ឯហិ ភោ ព្រាហ្មណ ហៃព្រាហ្មណ៍អើយ ចូរប្រស្ដែងមកអាយរ៉ា ។ កាលនោះ ជូជកព្រាហ្មណ៍ ឮព្រះបន្ទូលព្រះពោធិសត្វហើយ ក៏ដើរទន្ទបលបចូលជិតព្រះអង្គហើយ ថ្វាយបង្គំប្រណម្យ ទើបព្រះមហាសត្វទ្រង់តាំងព្រះហឫទ័យប្រាថ្នាព្រះសព្វញ្ញុតញ្ញាណ ហើយទ្រង់យកទឹកកុណ្ឌីស្រោច ទៅលើដៃព្រាហ្មណ៍មានព្រះបន្ទូលថា ព្រាហ្មណ៍អើយ ជាលីក្រស្នាជាកូនសម្លាញ់យើងពិត ថាបើនឹងប្រៀបផ្ទឹមនឹងជីវិតនោះ យល់ជាស្មើបាន តែយើងស្រឡាញ់សព្វញ្ញុតញ្ញាណក្រៃលែង ជាងព្រះរាជបុត្រទាំងពីរទាំងម៉ឺន ទាំងសែនគុណ ហើយព្រះអង្គយកព្រះរាជបុត្រទាំងពីរ ព្រះរាជទានឱ្យទៅជាទានព្រាហ្មណ៍ ។ ក្សណោនោះ ក្រឡាមហាប្រឹថពីកម្រើកអំពើក ឯព្រះឥន្ទ្រាធិរាជនិងអស់ពពួកទេវតាមហាព្រហ្ម ក៏បន្លឺ

Websites: WatKhemaraRatanaram.org or WatKhmers.org

នូវសព្ទអនុមោទនាថា ‹‹សាធុ សាធុ សាធុ›› ថាឱព្រះវេស្សន្តរអើយ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធទៀងប្រកដហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះ ៖

តតោ កុមារេ អាទាយ ជាលឹ កណ្ហាជិនំ ចុតោ
ព្រាហ្មណស្ស អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោ ។
តតោ កុមារេ អាទាយ ជាលឹ កណ្ហាជីនំ ចុតោ
ព្រាហ្មណស្ស អទា ចិត្តោ បុត្តកេ ទានមុត្តមំ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
យំ កុមារេ បទិន្នម្ហិ មេទនី សមកម្បថ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
យំ បញ្ជលិកតោ រាជា កុមារេ សុខវច្ឆិតេ
ព្រាហ្មណស្ស អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ហៃភិក្ខុអើយ នាកាលតថាគត នៅជាព្រះវេស្សន្តរបរ ពោធិសត្វ ជាស្តេចធំតែងចំរើនអ្នកស្រុកស្រីពិរាស្ត្រ ទ្រង់យកព្រះរាជ កុមារទាំងពីរ គឺថៅជាលី និងនាងក្រស្នា ព្រះរាជទានដល់ព្រាហ្មណ៍ ចាស់ជរាក្នុងគ្រាកាលនោះ ក៏កើតជាអស្ចារ្យមហិមា ក្រឡាមហា ប្រឹថពីកម្រើកកក្រើករញ្ជួយញាប់ញ័រ រីភ្នំព្រះសិនេរុរាជ ក៏សឹងឱន លំទោនទៅកាន់ភ្នំគិរីវង្កតបព៌ត រីព្រះឥន្ទ្រាធិរាជ ដ៏មានអំណាចជា ឥស្សរកំពូលនៃទេវតាទាំងឡាយ ក៏ទះព្រះហស្តទ្រង់ព្រះសម្រួល រីអស់ ទេវតានិងមហាព្រហ្ម ក៏ពោលពាក្យថ្វាយសព្ទសាធុការ ដ៏អធិកពន្លឹក មហិមានៅនាព្រៃហេមពាន្ត សឹងមានរាជសីហ៍ជាដើម ក៏សឹងស្រែក ទ្រហឹងអឺងអាប់នូវសព្ទពន្លឹកក្រៃពេក ។

មហាសត្តោ ឌាដំ ឧត្វា កាលព្រះបាទស្រីវេស្សន្តរបរម ពោធិសត្វ ទ្រង់ព្រះរាជទានព្រះរាជឱរសទាំងពីរទៅព្រាហ្មណ៍នោះ ហើយទ្រង់មានព្រះបីតិសោមនស្ស ថាទ្រង់បានឱ្យទានអស្ចារ្យណាស់ ហើយស្តេចបិតទតរមិលមើលព្រះរាជកុមារទាំងពីរក្នុងកាលណោះឯង

ជូជកោបិ វេគុម្ពំ បវិសិត្វា វល្លឹ ឧច្ឆេហិ ធិន្ទិត្វា អាដាយ

កាលនោះ ជូជកព្រាហ្មណ៍ បានព្រះរាជកុមារទាំងពីរមកនៅក្នុងកណ្ដាប់ដៃហើយកូវ ក៏ម្នីម្នារលះរលាំងចូលទៅក្នុងដង្ហុំព្រៃ ដៃប្រវាបោចវល្លិមកខាំកាត់នឹងធ្មេញបានហើយ ប្រវាចាប់ដៃឆ្វេងនាងក្រស្នា ប្រវាចាប់ដៃស្ដាំថៅជាលី បានហើយរូបគួបចងជាមួយគ្នា ហើយបណ្ដើរទៅ យកចុងវល្លិវាយដំនៅចំពោះព្រះភក្ត្រព្រះបាទស្រីវេស្សន្តរបវរពោធិសត្វនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អហ រីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនូវបាទព្រះគាថាដូច្នេះ ៖

តតោ សោ ព្រាហ្មណោ លុទ្ធោ លតំ ទន្តេហិ ឆិន្ទិយ
លតាយ ហត្ថេ ពន្ធិត្វា លតាយ អនុមជ្ជថ ។
តតោ សោ រជ្ជុមាទាយ ទណ្ឌញ្ចាទាយ ព្រាហ្មណោ
អាកោដយន្តោ តេ នេតិ សិវិរាជស្ស បេក្ខតោតិ ។

រីជូជកព្រាហ្មណ៍ វាយដំព្រះរាជកុមារទាំងពីរ មានសរីរៈបែកពុរពងរងឈាមក្រហមច្រាល នៅចំពោះព្រះភក្ត្រព្រះបាទស្រី

Websites: WatKhemaraRatanaram.org or WatKhmers.org

វេស្សន្តរ ។ កាលណាតាព្រាហ្មណ៍វាយនាងក្រស្នា ចៅជាលីយកខ្នងទៅរងតាង កាលបើវាយចៅជាលី នាងក្រស្នាក៏យកខ្នងទៅរងតាង តាជូជកចាប់អូសទាញកន្ត្រាក់នឹងខ្សែវល្លិ ទៅដល់ឋានមួយពុំរាប តាព្រាហ្មណ៍ដួលស្រប៉ាបខ្ចំប្រឹងស្ទុះក្រោកឡើងម្ដីម្នា រីព្រះហស្តព្រះរាជកុមារទាំងពីរដែលចងនឹងវល្លិ ក៏របូតចេញទៅ ទើបព្រះរាជកុមារទាំងពីរបបួលគ្នាម្ដីម្នា រត់ទៅកាន់សំណាក់ព្រះបរមពោធិសត្វ ថ្វាយបង្គំប្រណម្យ ហើយទ្រង់ព្រះកន្សែងសោកា ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់បាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយព្រះអង្គមានព្រះបន្ទូលជាបាទព្រះគាថាដូច្នេះ ៖

តតោ កុមារា បក្កាមុំ ព្រាហ្មណស្ស បមុញ្ចិយ
អស្សុបុណ្ណេហិ នេត្តេហិ បិតរំ សោ ឧទិក្ខតិ ។
វេធមស្សត្ថបត្តំវ បិតុ បាទានិ វន្ទតិ
បិតុ បាទានិ វន្ទិត្វា ឥទំ វចនមព្រវិ ។
អម្មា ច តាត និក្ខន្តា ត្វញ្ច នោ តាត ទស្សសិ

យាវ អម្ហំបិ បស្សេមុ អថ នោ តាត ទស្សសិ ។
មា នោ ត្វំ តាត អទទា យាវ អម្ហាបិ ឯតិ នោ
តទាយំ ព្រាហ្មណោ កាមំ វក្កីណាតុ ហនាតុ វា ។
ពលង្កចាទោ អន្ធនខោ អថោ ឱពទ្ធបិណ្ឌិកោ
ទីឃោត្តរោដ្ឋោ ចបលោ កឡារោ ភគ្គនាសកោ ។
កុម្ភោទរោ ភគ្គបិដ្ឋី អថោ វិសមចក្ខុកោ
លោហមស្សុ ហរិតកេសោ វលីនំ តិលកាហតោ ។
បិង្គលោ ច វិនតោ ច វិកដោ ច ព្រហា ខរោ
អជិនានិបិ សន្នទ្ធោ អមនុស្សោ ភយានកោ ។
មនុស្សោ ឧទាហុ យក្ខោ មំសលោហិតភោជនោ
គាមា អរញ្ញមាគម្ម ធនំ តំ តាត យាចតិ ។
នីយមានា បិសាចេន កិន្នុ តាត ឧទិក្ខសិ
អស្មា នូន តេ ហទយំ អយសា ទឡ្ហពន្ធនំ ។
យោ នោ ពន្ធេ ន ជានាសិ ព្រាហ្មណេន ធនេសិនា

Websites: WatKhemaraRatanaram.org or WatKhmers.org

អច្ចាយិកោន លុទ្ទេន　　　　　យោ នោ គាវោវ សុម្ភតិ ។
ឥទេវ អច្ឆតំ កណ្ហា　　　　　ន សា ជានាសិ កិស្មិញ្ចិ
មិគីវ ខីរសម្មត្តា　　　　　　យូថា ហីនា ។ កន្ទតីតិ ។

ភក្ខុអើយ លំដាប់នោះ ព្រះរាជកុមារទាំងពីរ ផុតរបូតពីកណ្ដាប់ដៃព្រាហ្មណ៍ ក៏នាំគ្នាម្នីម្នារត់មកក្រាបក្រោមព្រះបាទា នៃសម្ដេចព្រះវរបិតា មានទឹកព្រះនេត្រាហៀរហូរសស្រាក់ ញាប់ញ័រចម្រប់អស់អង្គប្រាណ ។ ថៅជាលីសម្លឹងមើលព្រះវរបិតា ហើយខំស្រដីថា បពិត្រព្រះវរបិតាអើយ សូមទានអម្ចាស់ ករុណាយើងខ្ញុំបន្ដិចសិនរ៉ា ទំរាំព្រះមេនៃយើងខ្ញុំ អ្នកត្រឡប់មកអំពីព្រៃ ដល់ថ្ងៃល្ងាចនឹងស្ដេចមកដល់ សូមអម្ចាស់លួងលោមព្រាហ្មណ៍ ឱ្យបង្អង់បន្ដិចសិន សឹមអម្ចាស់ឱ្យដំណើរយើងខ្ញុំនឹងព្រាហ្មណ៍ ។ បពិត្រព្រះវរបិតា កាលណាយើងខ្ញុំទាំងពីរបានក្រាបលាផ្ដាំផ្ញើអ្នកមេយើងខ្ញុំ នូវព្រះបាទអម្ចាស់រួចស្រេចហើយ សឹមយើងខ្ញុំដើរទៅតាមព្រាហ្មណ៍ដើម្បីបំពេញព្រះបារមីទានអម្ចាស់ ឱ្យបានត្រាស់ជាព្រះពុទ្ធប្រាកដហោង ។ បពិត្រព្រះវរបិតា វីព្រាហ្មណ៍នេះ វាអាក្រក់ក្រៃលែង

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រាហ្មណ៍ទាំងឡាយ វាប្រកបដោយបុរិសទោស ១៨ ប្រការ អកុសលកម្មនាំមកបង្កើតនៅនាលោកិយនេះ ពលង្គ៍ចាដោ នឹងគន់រមិលមើលទៅបាតជើងនោះធំស្នក់ដំបារកោងក្ងក់ អន្ធូនខោ ដ៏មានក្រចកម្រាមទាំង ១០ នោះ ខ្មៅស្អុយគ្រប់ទាំងអស់ ឱពទ្ធបិណ្ឌិកោ មានកំភូនជើងប្រកបដោយសាច់ដុំរយោងរយោងដូចផ្លែននោងទុំ ឌីឃុត្តរោដ្ឋោពពីរមាត់លើយុរយារគ្របពពីរមាត់ក្រោម ចបលោ កាលណាហាមាត់ស្រដីមានទឹកមាត់នោះហូរសស្រាក់ដោកថ្ពាល់ទាំងសងខាង ករាឡរោ មានចង្កូមសស្វាចដុះចេញពីមាត់ ដូចជាខ្នាយជ្រូក ភគ្គនាសកោច្រមុះនោះបាក់គន្លាក់ពុំស្មើ កុម្ភោឧរោ ពោះធំកំប៉ោង កំប៉ោក ៗប៉ុនក្អម ភគ្គបិដ្ឋិ មានខ្នងបាក់កោងក្ងក់ វិសមចក្ខុកោ ភ្នែកស្រលៀងស្រឡេវ ខ្ពស់ម្ខាងទាបម្ខាងមិនស្មើគ្នា លោហមស្សុ មានពុកចង្កាស្រមូវ រីងដូចលួសទង់ដែង ហរិតកេសោ រីសក់នោះច្រាលច្រាញ់រមួលកង្ហួញរួញលឿង មុខគួរខ្ពើម វលីនំ តិលកាហតោ តាមរាងកាយមានសរសៃឡើងរើមរវាម ហើយមានអាចម៍រុយ និងប្រជ្រុយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពេញសព្វខ្លួន ចិង្គលោ មានកែវភ្នែកលឿងដូចភ្នែកឆ្មា វិនតោ មានដង ខ្លួនវៀចកូក់ ត្រង់ក ត្រង់ខ្នង និងចង្កេះដូចជាគេធ្វើលេង វិកដោ ជើង ទាំងពីរក៏កន្ទែកញែកចេញពីគ្នាខុសធម្មតា ព្រហា ខរោ រោមតាមសព្វ ខ្លួនរឹងដូចរោមជ្រូក ខុសពីវិស័យមនុស្សធម្មតា ស្បៀកពាក់ស្បែកខ្លា មិនមែនមនុស្សមុខគួរស្នេហ៍ ជាមនុស្សឬជាយក្ស ដែលស៊ីតែសាច់ ឈាមទេក៏ពុំដឹង តាមា អរញ្ញ អាគម្ម ចេញពីស្រុកមកកាន់ព្រៃនេះ មានបំណងប៉ងចូលមកសុំទ្រព្យសម្បត្តិនឹងព្រះវរបិតា កាលព្រាហ្មណ៍ បិសាចនាំយកកូនទៅ វាវាយដំឥតប្រណី ម្ដេចឡើយអម្ចាស់នៅ ស្ងៀមព្រងើយ ពុំនាំពាព្រះហឫទ័យហាក់ដូចជាដុំថ្មសិលា ឬហាក់ ដូចជាគេចងរឹតដោយដែកយ៉ាងខ្ជាប់ខ្ជួន ឱព្រះវរបិតាអើយ ព្រះអង្គ ឥតព្រះទ័យអាសូរករុណាដល់កូនបន្តិចឡើយ តាព្រាហ្មណ៍មានចិត្ត កាចឃោរឃៅ ចង់បានតែទ្រព្យ ចាប់យកទៅវាយដំប្អូនក្រស្នាឥត មេត្តាសោះឡើយ មានគួរនាដូចនាយគោបាលវាយប្រហារហ្វូងគោ ដោយឥតមានចិត្តអាណិតអាសូរ ឱក្រស្នាមាសបងអើយ យើងទាំងពីរ នាក់នេះ បីដូចកូនម្រឹគដែលនៅកំពុងបៅដោះមេ ហើយព្រាត់ប្រាស

Websites: WatKhemaraRatanaram.org or WatKhmers.org

និរាសចាកមេទៅ កាលបើរកមេមិនឃើញ ក៏ស្រែកឃំរកមេក្នុងព្រៃព្រឹក្សា ប្រាថ្នាតែនឹងបៅដោះមេវាប៉ុណ្ណោះ ។ ព្រះគុណអើយ កូនទាំងគូនេះ កំសត់មកច្រើនគ្រាហើយ ពុំមានញាតិវង្សាឯណាដល់មួយឡើយ អម្ចាស់ខ្ញុំអើយ យល់តែមាតាបិតាមកគង់ក្នុងព្រឹក្សាជាសន្តានបើពុំទ្រង់ព្រះមេត្តាប្រោសប្រណី ខ្ញុំជាលីក្រស្នា ពុំដឹងបើអាស្រ័យនិងអ្នកឯណា ឱ្យក្រៃលែងលើសព្រះអង្គនេះឡើយ ។

កាលព្រះជាលីកុមារ ក្រាបបង្គំទូលព្រះវរបិតាយ៉ាងនេះហើយ ព្រះបាទស្រីវេស្សន្តរបវរាជឫសី ក៏ទ្រង់គង់នៅស្ងៀម មិនបានមានព្រះបន្ទូលដូចម្ដេចឡើយ ។ ព្រះរាជកុមារទាំងពីរក៏សោយសោកកន្ទក់កន្ទេញយ៉ាងមហិមា ក្រាបទូលទ្រង់ព្រះកន្សែងពិលាបដោយបាទព្រះគាថាទៅទៀតថា ៖

ន មេ ឥទំ តថា ទុក្ខំ    លព្ភា ហិ បមុជា ឥទំ
យញ្ច អម្មំ ន បស្សិស្សំ    តំ មេ ទុក្ខតរំ ឥតោ ។
ន មេ ឥទំ តថា ទុក្ខំ    លព្ភា ហិ បមុជា ឥទំ
យញ្ច តាតំ ន បស្សិស្សំ    តំ មេ ទុក្ខតរំ ឥតោ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

សា នូន កបណា អម្មា ចិរំ រត្តាយ រុច្ឆតិ
កណ្ហាជិនំ អបស្សន្តី កុមារឹ ចារុទស្សនឹ ។
សោ នូន កបណោ តាតោ ចិរំ រត្តាយ រុច្ឆតិ
កណ្ហាជិនំ អបស្សន្តោ កុមារឹ ចារុទស្សនឹ ។
សា នូន កបណា អម្មា ចិរំ រុច្ឆតិ អស្សមេ
កណ្ហាជិនំ អបស្សន្តី កុមារឹ ចារុទស្សនឹ ។
សោ នូន កបណោ តាតោ ចិរំ រុច្ឆតិ អស្សមេ
កណ្ហាជិនំ អបស្សន្តោ កុមារឹ ចារុទស្សនឹ ។
សា នូន កបណា អម្មា ចិរំ រត្តាយ រុច្ឆតិ
អឌ្ឍរត្តេវ រត្តេ វា នទីវ អវសុស្សតិ ។
សោ នូន កបណោ តតោ ចិរំ រត្តាយ រុច្ឆតិ
អឌ្ឍរត្តេវ រត្តេ វា នទីវ អវសុស្សតិ ។
ឥមេ តេ ជម្ពុកា រុក្ខា វេទិសា សិន្ទុវារិតា
វិវិធានិ រុក្ខជាតានិ តានិ អជ្ជ ជហាមសេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អស្សត្ថា បនសា ចេមេ　　និគ្រោធា ច កបិត្ថនា
វិវិធានិ ផលជាតានិ　　តានិ អជ្ជ ជហាមសេ ។
ឥមេ តិដ្ឋន្តិ អារាមា　　អយំ សីតូទកា នទី
យត្ថស្សុ បុព្វេ កីឡាម　　តានិ អជ្ជ ជហាមសេ ។
វិវិធានិ បុប្ផជាតានិ　　អស្មិំ ឧបរិ បព្វតេ
យានស្សុ បព្វេ ធារេម　　តានិ អជ្ជ ជហាមសេ ។
វិវិធានិ ផលជាតានិ　　អស្មិំ ឧបរិ បព្វតេ
យានស្សុ បុព្វេ ភុញ្ជាម　　តានិ អជ្ជ ជហាមសេ ។
ឥមេ នោ ហត្ថិកា អស្សា　　ពលិពទ្ទា ច នោ ឥមេ
យេហិស្សុ បុព្វេ កីឡាម　　តានិ អជ្ជ ជហាមសេតិ ។

វីព្រះរាជកុមារី ព្រះរាជកុមារ កាលអ្នកថ្វាយបង្គំលាទៅអ្នកសៅសោករអាក់រអួលតានតឹងក្នុងឱរាទាំងបងទាំងប្អូន ។ ព្រះវរបិតាពុំមានបន្ទូលស្ទងព្រះរាជបុត្រសោះឡើយ ទ្រង់ព្រះចិន្តាតែក្នុងព្រះរាជហឫទ័យឱ្យបានសម្រេចដូចក្ដីប្រាថ្នា ។ ឯចៅជាលីក៏បន្ទូល

ទៅនឹងនាងក្រស្នាថា «ឱក្រស្នាប្អូនអើយ ព្រះវរបិតាអ្នកយកយើងឱ្យទៅជាទានព្រាហ្មណ៍ម្ល៉េះហើយ សមយើងនឹងបានសេចក្ដីលំបាកវេទនា យើងនឹងចេញចាកទៅជាមួយនឹងព្រាហ្មណ៍ព្រឹទ្ធាចារ្យ គាត់នឹងវាយដំបែកហូរឈាមសព្វផ្លូវ ក្រស្នាប្អូនអើយ ធម្មតាសត្វនៅក្នុងលោកិយ សឹងតែជំពាក់នឹងក្ដីវដ្ដសង្សារ ពុំទាន់បានលុះព្រះពោធិញ្ញាណ គឺព្រះនិព្វានជាបរមសុខកាលណា តែងមានរោគាព្យាធិភ័យតាមមកទាន់អាត្មាពុំដែលរដោះ ទើបយើងត្រូវឃ្នាងខ្នោះ ច្រវាក់អន្ទាក់ណែងណងចងវាយ ដ៏ពុំដែលចៀសវាងបាន មានឧបមាបីដូចប្រាណយើងទាំងពីរនេះឯងហើយ ។ ឱក្រស្នាមាសបងអើយ នេះជាប្រពៃណីសព្វសត្វផង បងនេះបារម្ភត្បិតចាកព្រះមាតា ស្ដេចមកពីព្រឹក្សាដល់ព្រះអាស្រមសូន្យឈឹងជ្រងំស្ងប់ស្ងាត់តែម្នាក់ឯង ហើយអ្នកនឹងទ្រង់ព្រះកន្សែងសោយសោកា អ្នកនឹងទូញយំរកយើងទាំងពីរតាមដោយស្រះស្រង់សព្វម្លប់ឈើព្រៃ បើពុំឃើញយើងទាំងពីរហើយនៃ ឱក្រស្នាមាសបងអើយ សមអ្នកនឹងសោយសោកាសល់សែនអាមោក្ខពន់ប្រមាណ ននៀលប្រះប្រាណទូញយំ យកព្រះករដំព្រះឱរា

Websites: WatKhemaraRatanaram.org or WatKhmers.org

សោកស្តាយយើងជាកូនកំសត់ទាំងគូមកនៅក្នុងព្រៃ។ អ្នកមកពីព្រៃធ្លាប់បានយល់មុខយើងទាំងពីរ អ្នកត្រេកអរក្នុងព្រះទ័យបីថ្មមអាល័យ ហើយព្រះមេអ្នកឱ្យអស់ផលាសារពើ ដំឡូង ត្រាវ ចេក អំពៅ បង្គោសិរមាន់ ចន្ទន៍ ម័កប៉ែន គូលែន លាំងសាតគ្រប់សព្វពណ៌ផលា ហើយអ្នកនាំយើងចូលអាស្រមលំនៅ ហើយអ្នកបំបៅផ្ទូតទឹកដុសអស់អង្គ អ្នកយករមៀតផង់មកផាត់បំព្រង ទើបឱ្យយើងប្អូននិងបងឆីផលាផល សឹងដ៏មានរសពិសា តាមដោយនូវអាហារព្រៃភ្នំ លុះកាលវេលាល្ងាចនឹងចូលផ្ទំ តែងពិលាបទូញយំទាំងរាត្រី ប្រាមប្រាប់ប្រដៅសព្វសេចក្តីពុំឱ្យមានខ្វះ ត្បិតយើងលាកលះមកនៅក្នុងព្រឹក្សា ពុំមានញាតិវង្សាឯណាដល់មួយនាក់ឡើយ ។ អ្នកបានយល់តែមុខយើង ប្អូននិងបងនេះហើយ អ្នកគ្រាន់បានស្បើយលំហើយលំហែទុក្ខ ឥឡូវនេះអ្នកពុំបានយល់មុខយើងតទៅទៀតឡើយ ឱម្ល៉េះសមអ្នកនៅតែឯង សមនឹងសោកសង្រេងដួលសន្លប់ ពីល្ងាចព្រលប់លុះដល់ព្រឹក សមអ្នកនឹងសន្វែសន្ទឹកលុះតែអស់ព្រះកម្លាំង ដូចទឹកត្រពាំងខែប្រាំងត្រូវថ្ងៃក្តៅ ទឹកនោះក៏ស្រកស្រុតរីងហែងហួតស្ងួតខះបាត់បង់ទៅ ។ ក្រស្នា

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្អូនអើយ ទុក្ខនេះឃ្ងរលង់ក្រៃលែងទុក្ខផងទាំងឡាយ ដែលព្រាហ្មណ៍គាត់វាយដំធ្វើទោសយើងទាំងពីរនេះទៅទៀត ឥមេ តេ ជម្ពុកា រុក្ខា ប្អូនអើយ រីដើមជម្ពូព្រឹក្សអធិកនូវដើមពោធិ៍បាយ ដ៏មានមែកត្រសាយត្រសុំសាខា ម្លប់ព្រឹក្សាជាលំនៅដ៏សប្បាយ ដ៏មានព្រីង ព្រូស ភ្លូ ភ្លូង បង្គោ ដូង ដងអង្គាល់ ជ្រៃ ជ្រៃខ្ពស់ត្រឈឹងត្រឈៃឆើតឆាយ ឫសវាដុះវែងឆ្ងាយពាក់ព័ន្ធទៅមកទាក់សៀតស៊ករកគ្នា យើងតែងយកធ្វើជាទោងយោលលេង យើងច្រៀងលេងល្បែងក្រសាលសប្បាយ ព្រះពាយផាយផាត់ត្រជាក់ក្សេមក្សាន្ត បុប្ផាសោតសឹងមានដោយពណ៌ល្អ ៗ ក្រហម ខៀវ ស ល្អប្រសើរ ។ យើងតែងតែដើរទៅបេះយកបុប្ផាមកថ្វាយសៃមសៀតព្រះកេសា ប្រដាប់អស់អង្គប្រាណ ទាំងស្រះស្រង់ក៏សប្បាយ ទឹកថ្លាស្អាតមានផ្កាបទុមជាតិ ដុះដូចអ្នកចារ ទាំងផ្កាសត្បារ ឈូកច្រាល លឿង ស ល្អ ៗ ដុះជាជួរ ៗ ឯអស់មច្ឆាសោតក៏មានដោយហ្វូងទីទៃ ៗ យើងតែងប្រស្រ័យមើលលេងជាល្បែងសព្វវេលា ឥមេ នោ ហត្ថិកា អស្សា ឱស្តាយរូបម្រឹគ សេះ ដំរី គោ ទន្សាយ

រមាំង ប្រើស ទ្រាយ គជសីហ៍ ដែលព្រះវរបិតា ទ្រង់សូន្យព្រះរាជទាន ឱ្យយើងលេង ។ ឥឡូវនេះ យើងបង់ល្បែង ព្រាត់ប្រាសពីទីសប្បាយ ចេញទៅនៅឆ្ងាយ ធ្វើជាខ្ញុំព្រាហ្មណ៍នេះហោង» ។

ភិក្ខុវេ ម្នាលសង្ឃដ៏ទ្រង់នូវសីល សមាធិ បញ្ញា នាកាលព្រះជាលីកុមារ កំពុងពិលាបកន្សែងក្រាបទូលព្រះវរបិតា ឯតាជូជកព្រឹទ្ធាចារ្យក៏តាមមកទាន់ វាយដំ ចាប់ចងព្រះរាជកុមារទាំងពីរ នៅចំពោះព្រះភក្ត្រព្រះវរបិតា ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះគាថាឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលជាបាទព្រះគាថាដូច្នេះ ៖

ឥទំ មាតា កុមារា តេ បិតរំ ឯតទព្រវុំ
អម្មំ អារោគ្យំ វជ្ជាសិ ត្វញ្ច តាត សុខី ភវ ។
ឥមេ នោ ហត្ថិកា អស្សា បលិពទ្ធា ច នោ ឥមេ
តានិ អម្មាយ ទជ្ជាសិ សោកន្តេហិ វិនេស្សតិ ។
ឥមេ នោ ហត្ថិកា អស្សា ពលិពទ្ធា ច នោ ឥមេ

តានិ អម្ម ឧជិក្ខន្តី សោកំ បដិវិនេស្សតីតិ ។

ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីព្រះរាជកុមារទាំងពីរ ដែលតាជីចាស់ជរាកំពុងតែមកចាប់នាំយកទៅនោះ បានក្រាបទូលព្រះជនកដូច្នេះទៀតថា «បពិត្រព្រះជនកអើយ សូមទានអម្ចាស់ត្រាស់ប្រាប់ព្រះមេយើងខ្ញុំផងថា យើងខ្ញុំទាំងពីរជាលីក្រស្នា សុខសប្បាយឥតរោគាព្យាធិមកបៀតបៀនឡើយ» ។ បពិត្រព្រះវរបិតាអើយ ឯព្រះអង្គសោត ក៏សូមឱ្យប្រកបដោយសេចក្ដីសុខសប្បាយគ្រប់ទិវារាត្រី **ឥមេ ចោ ហត្ថិកា អស្សា** បពិត្រអម្ចាស់អើយ រីសំនួន ដំរី ពាជី គោ តោ សិង្ហ រាជសីហ៍ ដែលអ្នកសូន្យនឹងដី ឱ្យយើងខ្ញុំលេងជាល្បែងតែសព្វថ្ងៃនោះ សូមព្រះអង្គប្រគល់ បង្ហាញទៅព្រះមេឱ្យទានផង ក្រែងព្រះមេយើងខ្ញុំអ្នកយល់សំនួននោះហើយ ព្រះមេយើងខ្ញុំនឹងបន្ទោបង់សេចក្ដីសៅសោកបានខ្លះ សោះអ្នកនឹងរលឹកយើងទាំងពីរពន់ពេក ។

តតោ មហាសត្តស្ស បុត្តេ អារព្ភ ពលវសោកោ ឧប្បជ្ជិ ហទយមំសំ ឧណ្ហំ អហោសិ ។ កាលនោះ ព្រះបាទស្រីវេស្សន្តរបរវ

Websites: WatKhemaraRatanaram.org or WatKhmers.org

មហាសត្វ ស្តេចស្តាប់ពាក្យព្រះរាជកុមារ ទ្រង់ព្រះកន្សែងពិលាបជាពន្លឹកដូច្នោះ ព្រះអង្គក៏មានព្រះហរឫទ័យសៅសោក អាណិតអាសូរព្រះរាជបុត្រទាំងពីរលើសលន់ពន់ប្រមាណ មានព្រះហឫទ័យក្តៅផ្សានៅពុំស្រណុករអាក់រអួល ក្នុងព្រះឱរាញ៉រចំប្រប់អស់ទាំងព្រះអង្គ មានឧបមាបីដូចកេសររាជសីហ៍ចាប់ដំរីសារចុះប្រេង ឬមួយដូចព្រះចន្ទ្របានចំណាប់ព្រះរាហូ បណ្ណសាលំ បវិសិត្វា ទើបស្តេចចូលទៅកាន់បណ្ណសាលា មានព្រះហឫទ័យក្រៀមក្រំជាំព្រះភក្ត្រា ទ្រង់ព្រះចិន្តាគន់គិតអាណិតព្រះរាជបុត្រ ញាប់ញ័រអស់ទាំងព្រះកាយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រជាបាទព្រះគាថាដូច្នេះ ៖

តតោ វេស្សន្តរោ រាជា ជាជំ ឧត្វាន ខត្តិយោ
បណ្ណសាលំ បវិសិត្វា កលូនំ បរិទេវយីតិ ។

លំដាប់នោះ ព្រះបាទស្រីវេស្សន្តរ លុះស្តេចព្រះរាជទានព្រះរាជបុត្រទាំងពីរទៅព្រាហ្មណ៍ហើយ ស្តេចចូលទៅក្នុងព្រះបណ្ណ-

សាលា ទ្រង់ព្រះកន្សែងសោកាពិលាបយោបំច្រើនមហិមា ។ លំដាប់តពីនោះ ព្រះបរមពោធិសត្វទ្រង់ថ្លែងព្រះពិលាបជាបាទព្រះគាថាដូច្នេះ

កន្វជ្ជច្ឆាតា តសិតា ឧបរុច្ឆន្តិ ទារកា
សាយំ សំវេសនាកាលេ កោ នេ ទស្សតិ ភោជនំ ។
កន្វជ្ជច្ឆាតា តសិតា ឧបរុច្ឆន្តិ ទារកា
សាយំ សំវេសនាកាលេ អម្ម ច្ឆាតម្ហ ទេថ នោ ។
កថន្នុ បថំ គច្ឆន្តិ បត្តិកា អនុចាហនា
សន្តា សុណេហិ ចាទេហិ កោ នេ ហត្ថេ គហេស្សតិ ។
កថន្នុ សោ អលជ្ជេយ្យ សម្មុខា បហារំ មម
អទូសកានំ បុត្តានំ អលជ្ជី វត ព្រាហ្មណោ ។
យោបិមេ ទាសីទាសស្ស រញ្ញោ វា បន បេសិយា
តស្សាបិ សុវិហីនស្ស កោ លជ្ជី បហរិស្សតិ ។
វារិជស្សេវ មេ សតោ ពន្ធស្ស កុមិនោ មុខេ
អក្កោសតិ បហរតិ បិយេ បុត្តេ អបស្សតោតិ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱកូនសម្លាញ់ទាំងពីរឪពុកអើយ ថ្ងៃល្ងាចថ្ងៃនេះហើយ សមបានឹងឃ្លានអាហារ នរណានឹងរមិលមើលឱ្យអាហារអ្នកផង យល់តែតាជូជកព្រឹទ្ធាចារ្យ នឹងមានតែសេចក្ដីភ័យតក់ស្លុតមហិមា អ្នកស្រេកទឹក នរណានឹងបំផឹក កូនសង្សារឪពុកអើយ នាថ្ងៃល្ងាចស្រយាលម្ល៉េះហើយ បាធ្លាប់វែងទារអាហារម្ដាយថា បពិត្រអ្នកមេអើយ យើងខ្ញុំឃ្លានបាយ ម្ដាយបាក៏រកចំណីឱ្យផង អ្នកស្រេកទឹកម្ដាយអ្នកក៏រកទឹកឱ្យផឹកម្ល៉េះហើយបានឹងទារនរណា ៗ នឹងករុណាប្រណីឱ្យចំណីបាផង គាថន្ទុ បចំ គច្ឆន្តិ ឱកូនស្ងួនឪពុកអើយ អាសូរបាតជើងរៀវតូចដើរជាន់លើខ្សាច់ក្ដៅ មុខជាពុរពងបែកហូរឈាមត្រូវព្រាហ្មណ៍ចងវាយបណ្ដើរទៅ គោ នេ ហត្ថេ គហេស្សតិ កូនអើយនរណានឹងដឹកដៃបាកំដរ ដើរដោយមាគ៌ា គាចំ សោ ន លជ្ជេយ្យ ឱដូចអញគិតនេះហើយ ព្រាហ្មណ៍នោះវាឥតខ្មាសអ្វីមាល្បាយ វាវាយបញ្ជោះនៅមុខអញពុំត្រាប្រណី ហើយនាំបណ្ដើរទៅ លើសក្រៃលែងជាងខ្ញុំលោះនឹងប្រាក់ចាក់ពីថង់ យោបិ មេ ធាសីធាសស្ស អញ្ញោ វា បន បេសិយោ ទោះអ្នកឯណាមួយមកធ្វើជាខ្ញុំប្រុសខ្ញុំស្រីនៃអញ ទោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

យោបីខុសគាប់អម្បាលម៉ាន គេញ៉ាំងគិតក្រែងចិត្តថាជាខ្ញុំព្រះបាទស្រីវេស្សន្តរ គេកោតខ្លាចអំណាចពុំអាចវាយដំឡើយ ។ ឯព្រាហ្មណ៍កញ្ចាស់កន្ទ្រើសឫស្យា សាហាវយង់ឃ្នងឥតខ្មាស វាវាយដំនឹងឈើច្រត់ វាត់នឹងចុងវល្លិ ដាលបែកឈាមហូរសស្រាក់នៅចំពោះមុខអញឥតចិត្តអាណិតអាសូរបន្តិចឡើយ **ភរិជស្សេវ មេ សតោ ពន្ធស្ស កុមិដោ មុខេ** ជូជកព្រាហ្មណ៍វាជេរស្តី វាយដំកូនទាំងពីរជាទីស្រឡាញ់នៅចំពោះមុខអញនេះ អញក្តៅចិត្តពន់ពេកណាស់ អញគិតមើលទៅ កូនអញទាំងពីរដូចកលត្រីចូលទ្រូ នឹងថយមកក្រោយទាល់នឹងផ្ទុក រុលទៅមុខទាល់នឹងប្រឹស ព្រះបរមពោធិសត្វទ្រង់ព្រះកន្សែងសោកពិលាប ដោយស្រឡាញ់ព្រះរាជបុត្រទាំងពីរលើសលន់ពន់ប្រមាណ ។ ព្រះអង្គរិះគិតតែក្នុងកំឡុង ព្រះរាជហឫទ័យថា ‹‹ព្រាហ្មណ៍កញ្ចាស់វាបៀតបៀនកូនអញអ្វីមាល្បាយអេះ›› ទ្រង់ត្រិះរិះដូច្នោះហើយ ព្រះអង្គមិនអាចទប់ទល់ព្រះកន្សែងសោកបានឡើយ ទើបទ្រង់ព្រះចិន្តាថា ‹‹អាត្មាអញតាមទៅកាត់កព្រាហ្មណ៍កញ្ចាស់នោះក៏បានអេះ›› យកកូនអញត្រឡប់មកវិញក្នុងកាលឥឡូវនេះឯង ។

លុះព្រះមហាក្សត្រ ទ្រង់ត្រិះរិះដូច្នេះហើយ បែរជាទ្រង់ព្រះចិន្តាក្នុងព្រះទ័យវិញថា «ធម្មតាអ្នកមានធម៌សប្បុរសតាំងចិត្តប្រាថ្នាជាព្រះពុទ្ធ នាំសត្វឆ្លងវដ្តសង្សារ បានយកកូនឱ្យទៅជាទានស្មូមហើយ យល់តែស្មូមវាធ្វើទុក្ខទោសកូនដល់ម្ល៉ោះកូវ ត្រឡប់ជាប្រែខ្វេចិត្តគំនិត គិតក្តៅក្រហាយស្តាយក្រោយ ហើយមានគំនិតគិតទៅធ្វើទុក្ខទោសគេវិញនោះ មិនសមគួរឡើយ មានព្រះបរិវិតក្កគាថា ថ្លែងព្រះតម្រិះនៃព្រះបរមពោធិសត្វនោះ ឱ្យចែងច្បាស់ដូច្នេះថា ៖

អាទុ ចាបំ តហោត្វាន ខត្តំ ពន្ធិយ វាមតោ
អានិស្សាមិ សតោ បុត្តេ បុត្តានំ ហិ វធោ ទុក្ខោ ។
អដ្ឋានមេតំ ទុក្ខរូបំ យំ កុមារា វិហញ្ញរេ
សតញ្ច ធម្មញ្ញាយ កោ ទត្វា អនុតប្បតីតិ ។

ហៃភិក្ខុផងទាំងឡាយអើយ កាលព្រះបាទស្រីវេស្សន្តរបរមបពិត្រ ទ្រង់គិតរំពឹងក្នុងព្រះរាជហាឫទ័យថា អញនឹងយកព្រះកៅទ័ណ្ឌ នូវព្រះខ័នសថ្លា ស្ពាយស្មាខាងឆ្វេង ហើយអញនឹងតាមទៅសម្លាប់ព្រាហ្មណ៍ឱ្យក្ស័យជីវិត សឹមអញយកកូនអញទាំងពីរវិល

Websites: WatKhemaraRatanaram.org or WatKhmers.org

មកវិញ ត្បិតវាពុំស្រឡាញ់ស្ងួនគ្រងឡើយ វាតែងបៀតបៀនវាយដំកូនអញជាពន្លឹកមហិមា ឱ្យជាទុក្ខពេកពន់ប្រមាណ ។ ព្រះបរមពោធិសត្វ ទ្រង់ខ្ញាល់នឹងព្រាហ្មណ៍នោះមហិមា តែងដោយហេតុព្រះអង្គស្រឡាញ់ប្រាថ្នាសព្វញ្ញុតាញាណនោះខ្លាំងណាស់ ទើបខ្ញែប្រែព្រះរាជហឫទ័យគិតថា «ឱ! បាវេស្សន្តរអើយ រីទុក្ខឯណាដែលព្រាហ្មណ៍វាវាយដំបៀតបៀនកូនទាំងពីរ រីទុក្ខមានភាពដូច្នោះ អង្គឹជាឋានជាហេតុ នឹងទៅបៀតបៀនព្រាហ្មណ៍នោះឡើយ» ធម្មតាប្រពៃណីនៃព្រះបរមពោធិសត្វ ឱ្យកូនសង្សារទៅជាទានហើយ លោកមិនដែលក្តៅក្រហាយស្តាយក្រោយឡើយ ។

រីព្រះពោធិសត្វ ព្រះអង្គរំលឹកទៅដល់ប្រពៃណី នៃព្រះពោធិសត្វអំពីបុរាណហើយ ដែលលោកប្រាថ្នាជាព្រះពុទ្ធនោះ លោកមិនដែលខានធ្វើមហាបរិច្ចាគទាំង ៥ ប្រការ គឺធនបរិច្ចាគ ១, អង្គបរិច្ចាគ ១, ជិវិតបរិច្ចាគ ១, បុត្តបរិច្ចាគ ១, ភរិយាបរិច្ចាគ ១ ។ លុះតែធ្វើមហាបរិច្ចាគនោះនៃ ទើបបានត្រាស់ជាព្រះពុទ្ធហោង ។ ឯអញសោតបើមិនបានចូលក្នុងលង្វែកព្រះពោធិសត្វអំពីបុរាណ មិនបាន

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱ្យប្រពន្ធកូនជាទានឡើយ នាបីអញប្រាថ្នានឹងឱ្យបានត្រាស់ជាព្រះពុទ្ធនោះមិញមិនបានឡើយ ។ កាលព្រះអង្គទ្រង់ត្រិះរិះដូច្នោះហើយទើបដៀលត្មះព្រះអង្គឯងថា ‹‹ហៃបាវេស្សន្តរអើយ បាមិនដឹងទេឬការឱ្យទានកូនទៅធ្វើជាខ្ញុំអ្នកដទៃនោះវាជាទុក្ខ ក៏បាសឹងដឹងស្រាប់ហើយតើ ហេតុអ្វីឡើយ ក៏បាគិតទៅតាមសម្លាប់ព្រាហ្មណ៍នោះមិញ›› ធម្មតាអស់អ្នកផងតែគេឱ្យទានហើយ គេមិនដែលថុចថយក្រោយដូចបានេះឡើយ ។ ហេតុនេះ តាំងអំពីថ្ងៃនេះទៅ កុំថាព្រាហ្មណ៍វាវាយដំនាំទៅឡើយ សូម្បីវានឹងសម្លាប់កូនអញបង់ទៅក្ដី ស្រេចនូវអំពើពុតវាចុះ ។ រីព្រះបរមពោធិសត្វ ព្រះអង្គទ្រង់អធិដ្ឋានសមាទានខ្ជាប់នូវទានបារមី តម្កល់ទុកក្នុងព្រះហឫទ័យហើយ ទើបស្ដេចចេញអំពីបណ្ណសាលាមកគង់នាមាត់ទ្វារលើដំបារថ្ម មានព្រះអង្គនោះល្អបី ដូចរូបបដិមាមាស គិតដ៏ជាងអ្នករចនា ប្រពៃពេកក្ដាត់ហោង ។

ឌូជកោបិ បពិត្រអើយ រីតាជូជកចាស់ព្រឹទ្ធាចារ្យ ដោះឡើងអំពីដួលកាលណា ក៏ម្ទីម្នាប្រវាចាប់បានឈើច្រត់រត់ទន្ទាំគម្រាមងងាម តាមមកចាប់ព្រះរាជកុមារទាំងពីរ វាយដំនៅចំពោះព្រះភក្ត្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះបរមពោធិសត្វ ហើយចងនាំបណ្ដើរយកទៅវិញ ។ កាលនោះ ព្រះរាជកុមារទាំងពីរ ទ្រង់ព្រះកន្សែងសោកពិលាបមហិមា ចៅជាលីមានបន្ទូលទៅនឹងនាងក្រស្នាដូចមានព្រះគាថាដូច្នេះ ៖

សច្ចំ កិរេវមាហំសុ    នរា ឯកច្ចិយា ឥធ
យស្ស នត្ថិ សកា មាតា    យថា នត្ថិ តថេវ សោ ។
ឯហិ កណ្ហេ មរិស្សាម    នត្ថត្ថោ ជីវិតេន នោ
ទិន្នម្ហាបិ ជនិន្ទេន    ព្រាហ្មណស្ស ធនេសិនោ
អច្ចាយិកស្ស លុទ្ធស្ស    យោ នោ គាវោវ សុម្ភតិ ។
ឥមេ តេ ជម្ពុកា រុក្ខា    វេទិសា សិន្ទុវារិតា
វិវិធានិ រុក្ខជាតានិ    តានិ កណ្ហេ ជហាមសេ ។
អស្សត្ថា បនសា ចេមេ    និគ្រោធា ច កបិត្ថនា
វិវិធានិ ផលជាតានិ    តានិ កណ្ហេ ជហាមសេ ។
ឥមេ តិដ្ឋន្តិ អារាមា    អយំ សីតូទកា នទី
យត្ថស្សុ បុព្វេ កីឡាម    តានិ កណ្ហេ ជហាមសេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

វីជានិ បុប្ផជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្ស បុព្វេ ជាវេម តានិ កណ្ហេ ជហាមសេ ។
វីជានិ ផលជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្ស បុព្វេ កុញ្ជាម តាន កណ្ហេ ជហាមសេ។
ឥមេ នោ ហត្ថិកា អស្សា ពលិពទ្ធា ច នោ ឥមេ
យេហិស្ស បុព្វេ កីឡាម តានិ កណ្ហេ ជហាមសេ ។

កណ្ហេ ហៃនាងក្រស្នាប្អូនពុំងាបងអើយ បងធ្លាប់បានឮថា អ្នកប្រាជ្ញពួកខ្លះ នាលោកិយនេះ ស្រដីមែនពិតអ្វីមាល្បាយម្ល៉េះ ថាបើអ្នកឯណាកើតមកអំពីឧទរម្តាយហើយ គឺមោះពុំទាន់ធំ នៅជាក្មេងតូចដូចយើងនេះឯង ល្គឹកបើម្តាយព្រាត់ប្រាសនិរាសទីទៃហើយ ក្រស្នាមាសបងអើយ ក្មេងនោះលោកទុកដូចជាស្លាប់ពិត ។ មក ក្រស្នាមាសបង យើងទាំងពីរស្លាប់ទៅប្រសើរជាង មានជីវិតរស់នៅថ្វី ព្រះវរបិតាព្រះរាជទានឱ្យទៅតាចាស់ ចិត្តសាហាវយង់ឃ្នង វាយដំយើងទាំងពីរឥតត្រាប្រណី ដូចជាគង្វាលគោវាយហ្វូងគោ គ្មានមេត្តាប្រណីដល់តិចឡើយ ឥមេ តេ ជម្ពុកា រុក្ខា ឱក្រស្នាមាសបងអើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ស្រណោះដើមជម្ពូព្រឹក្ស អធិកនូវមែកសាខាបុប្ផាសន្លឹកស្រណុក មហិមា ជាក្រយាបន្លែងយើងមិញ ឱម្ល៉េះហើយ សមយើងប្រាសចេញពីឈើអស់នោះហើយ ។ ឱក្រស្នាប្អូនអើយ រីខ្នុរណាំង ក្រសាំ រាំង ជ្រៃ ពៃ ពោត ដ៏ប្រកបនូវផ្លែផ្កា ច្រើនស្អេកស្កះរីកស្គុសស្គាយ សឹងដ៏មានពណ៌ផ្សេង ៗ សឹងប្រាសនិរាសអស់ហើយ ។ ក្រស្នាមាសបងអើយ រីសំនួនដំរី ពាជី គោឆ្មាត់ ព្រះជនកធ្លាប់សូនឱ្យជាល្បែងលេងកំសាន្តនៃយើង ក្រស្នាអើយ ឥឡូវត្រូវប្រាសនិរាសអស់ហើយ ។

បុន ព្រាហ្មណោ ឯកស្មឹ វិសមដ្ឋានេ បក្ខលិត្វា បតតិ បពិត្រអើយ រីជូជកព្រាហ្មណ៍នាំកុមារទាំងពីរ ដើរទៅដល់ទីមួយមិនរាបទាប ខំសង្វាតដើរខ្លាំង ពពីបពពាបភ្លាត់ជើងជំពប់ដួលស្រប៉ាបទៅម្តងទៀត ពុំបានដោះឡើងឆាប់ ៗ អណ្តាប់នោះ ចៅជាលីនិងនាងក្រស្នា កាលណាបានរបូតចេញពីចំណងព្រាហ្មណ៍ មានរាងកាយញ័ររន្ធត់សព្វអង្គប្រាណ មានឧបមាដូចមាន់ដែលគេប្រហារ ទើបព្រះរាជកុមារទាំងគូ បបួលគ្នាម្នីម្នារត់ទៅកាន់ព្រះវរបិតា យ៉ាងរូតរះប្រញាប់ប្រញាល់ឥតបង្អង់ឡើយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់

Websites: WatKhemaraRatanaram.org or WatKhmers.org

ប្រាកដ បទព្រះគាថាឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយថា ៖

ជីយមានា កុមារា តេ ព្រាហ្មណស្ស បមុញ្ចិយ

តេន តេន បជាវីសុ ជាលី កណ្ហាជិនា ចុភោតិ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ រីចៅជាលី និងនាងក្រស្នា កាលណាព្រាហ្មណ៍នោះដួលស្រប៉ាប់ទៅ ក៏បបួលគ្នារត់ចេញទៅកាន់សំណាក់ព្រះវរបិតា មានអាត្មាញ័ររន្ធត់ ។ កាលនោះ ជូជកព្រាហ្មណ៍ដោះឡើងម្ទីម្នាយ៉ាងប្រញាប់ ចាប់បានវល្លិ នូវឈើច្រត់រត់ទៅទាំងក្ដៅចិត្ត គាត់ខឹងមហិមាដូចជាភ្លើងឆេះកល្ប ថាពះអាក្មេងរបឹងរឹងរូស ប៉ុនរត់អ្វីមាល្បាយ អញនឹងវាយឱ្យបែកខ្នងឥឡូវនេះឯងមិនទេឡើយ តាចាស់ចាប់ចងខ្ជាប់ហើយវាយនឹងឈើច្រត់ ទាត់នឹងជើងឥតត្រាប្រណី ស្រដីគម្រាមតឿនថា ‹‹បើមឹងមិនដើរ ត្រូវឈើច្រត់ជីពុកកញ្ជាស់ឥឡូវនេះឯង›› ។

តមត្ថំ កាសេដ្ឋោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គត្រាស់នូវព្រះគាថាដូច្នេះថា ៖

Websites: WatKhemaraRatanaram.org or WatKhmers.org

តតោ សោ រុទ្ទមានាយ    ធណ្ហាញ្ញាតាយ ព្រាហ្មណោ
អកោជយន្តោ តេ នេតិ    សិវិរាជស្ស បេក្ខតោតិ ។

ព្រាហ្មណ៍ជរាមានចិត្តឃោរឃៅ ចាប់បានវល្លិនិងឈើច្រត់ តាមទៅចងវាយបណ្ដើរព្រះរាជកុមារទាំងពីរ នៅចំពោះមុខព្រះភក្ត្រ ព្រះបាទស្រីវេស្សន្តររាជឫសី ឥតបីមានសេចក្ដីកោតក្រែងស្ញែងចិត្ត ដល់តិចឡើយ ។

រីនាងក្រស្នា កាលណាព្រាហ្មណ៍ចាស់ចាប់កន្ត្រាក់ អូស ទាញយកទៅ នាងក៏ងាកបែរមកទ្រង់ព្រះកន្សែងពិលាប ក្រាបទូល អង្វរព្រះជនក មុខគួរឱ្យអាសូរករុណាពន់ប្រមាណ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ ប្រាកដ បទព្រះបាលីឯណាពុំទាន់ថៃងច្បាស់ លុះព្រះបានត្រាស់ ហើយ ព្រះអង្គបានប្រកាសសម្ដែងនូវគាថាដូច្នេះ ៖

តំ តំ កណ្ហាជិនាវោច    អយំ មំ តាត ព្រាហ្មណោ
លដ្ឋិយា បដិកោដេតិ    ឃរេ ជាតំវ ទាសិយំ ។
ន ចាយំ ព្រាហ្មណោ តាត    ធម្មិកា ហោន្តិ ព្រាហ្មណា

Websites: WatKhemaraRatanaram.org  or  WatKhmers.org

យតោ្វា ព្រាហ្មណវណ្ណេន ខាទិតុំ តាត នេតិ នោ
ជីយមានា បិសាចេន ភិន្ទុ តាត ឧទិក្ខសីតិ ។

ភិក្ខុវេ ហៃភិក្ខុផងទាំងឡាយអើយ កាលនោះ នាងក្រស្នាទ្រង់ព្រះកន្សែង ក្រាបទូលព្រះវរបិតាថា «បពិត្រព្រះជនកអើយ ព្រាហ្មណ៍នេះ វាវាយខ្ញុំនឹងឈើច្រត់ឈើផ្សាមហិមា ហាក់ដូចជាខ្ញុំកើតក្នុងផ្ទះវា មិនមែនជាបុត្រីអម្ចាស់ឡើយ បពិត្រព្រះជនកអើយ ធម្មតាព្រាហ្មណ៍ទាំងឡាយ តែងមានធម៌សប្បុរស ឯព្រាហ្មណ៍ចាស់នេះខុសក្រៅច្បាប់ធម៌លើសលន់ ទុជិនឥតសប្បុរសសោះឡើយ បពិត្រព្រះជនកអើយ តាចាស់នេះ ម្រាងវាជាព្រាហ្មណ៍ពិតពំនិតមកសូមយើងខ្ញុំទៅធ្វើជាខ្ញុំ តម្កល់ជាយក្សធំស្គមស្លេ យកភៀសជាព្រាហ្មណ៍ទំរាំតែបានយើងទាំងពីរយកទៅឆីសាច់ទេដឹង បពិត្រព្រះជនកអើយ បើដូច្នេះ តើម្តេចក៏ព្រះអង្គបណ្តោយ ឱ្យតាបិសាចនាំយកយើងទៅ ម្តេចព្រះអង្គមិនពិចារណាអាណិតអាសូរដល់តិចឡើយ ។

កាលនាងក្រស្នាកុមារីក្សត្រី ក្រាបទូលព្រះវរបិតាដូច្នោះហើយ ក៏ញ៉ូររន្ធត់អស់អង្គប្រាណ ព្រាហ្មណ៍ក៏ចាប់អូស ដឹកយកទៅ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឥតប្រណី ព្រះមហាក្សត្រក៏ទ្រង់ព្រះកន្សែង សោយសោកាណាស់អំពល់នូវទុក្ខ កើតមានព្រះហឫទ័យក្តៅអួលអាក់ តានតឹងព្រះឱរាទាល់តែព្រះភក្ត្រឡើងក្រហមទុំ រាលដាលដល់ព្រះនាសា ត្រាតែដកដង្ហើមចេញចូលពុំបានស្រួល តោងដកដង្ហើមតាមព្រះឱស្ឋ ស្រក់ទឹកព្រះនេត្រទៅសឹងជាឈាម ទើបព្រះអង្គរំពឹងសញ្ជឹងក្នុងព្រះរាជហឫទ័យថា «ឱទុក្ខអញនេះធ្ងន់ពន់ប្រមាណមាល្បាយអេះ» នេះក៏កើតមកតែអំពីសេចក្តីស្នេហាស្រឡាញ់ បើដូច្នេះត្រូវអញកាត់បំបាត់ចិត្តស្រឡាញ់ស្នេហា ឱ្យជ្រះស្រឡះចេញពីសង្សារវដ្ត ។ ទើបព្រះពោធិសត្វ ព្រះអង្គយកព្រះប្រាជ្ញាសពេជ្ញូតាញាណ មកបន្ទោបង់សេចក្តីស្រឡាញ់ស្នេហាបានហើយ ព្រះអង្គគង់នៅស្ងៀម ដូចតាមប្រក្រតីហោង ។

រីព្រះរាជកុមារទាំងពីរ តាជូជកព្រាហ្មណ៍តាមចាប់ក្រឡាប់នាំទៅឆ្ងាយទូរគម តែនៅពុំទាន់ដល់មាត់ទ្វារព្រៃនៃភ្នំគិរីវង្កត នាងក្រស្នាក្សត្រីពុំងា រវឹងទ្រង់ព្រះកន្សែងយោបំពិលាបដរាបទៅដោយមាគ៌ា ដូចមានបាទព្រះគាថាទាំងឡាយថាដូច្នេះ ៖

ឥមេ នោ ចាទុកា ទុក្ខា ជីយោ ចន្ទា សុទុក្ខមោ
នីចេ ពោលម្ពកោ សុរិយេ ព្រហ្មណោរ តរេតិ នោ ។
ឱកណ្ណាម្ពសេ ភូតានិ បព្វតានិ វនានិ ច
សរស្ស សិរសា វន្ទាម សុបតិត្ថេ ច អាបកោ ។
តិណា លតានិ ឱសធ្យោ បព្វតានិ វនានិ ច
អម្ហំ អាពេក្យំ វន្ទាថ អយំ នោ នេតិ ព្រាហ្មណោ ។
វន្ទន្តុ ភោន្តោ អម្ហញ្ច មទ្ទិំ អស្មាក មាតរំ
សចេ អនុប្បតិតុកាមា ខិប្បំ អនុប្បតេយ្យ នោ ។
អយំ ឯកបទី ឯតិ ឧជុំ គច្ឆតិ អស្សមំ
តមេវានុប្បតេយ្យាសិ អបិ បស្សេសិ នោ លហុំ ។
អហោ វត រេ ជដិនី វនមូលផលហារិយា
សុញ្ញំ ទិស្វាន អស្សមំ តន្តេ ទុក្ខំ ភវិស្សតិ ។
អតិវេលំ នុ អម្មាយ ឧញ្ឆាលទ្ធំ អនប្បកំ
យា នោ ពន្ធេន ជានាតិ ព្រាហ្មណេន ជនេសិតា ។

Websites: WatKhemaraRatanaram.org or WatKhmers.org

អច្ចាយិកេន លុទ្ទេន　　យោ នោ គាវេ សុម្ភតិ
អបជ្ជ អម្ហំ បស្សេមុ　　សាយំ ឧញ្ឆាតោ អាគតំ ។
ឧជ្ឈា អម្ហា ព្រាហ្មណស្ស　　ផលំ ខុទ្ទេន មិស្សតំ
តទាយំ អាសិតោ ឆាតោ　　ន ពាឡ្ហំ តរយេយ្យ នោ ។
សុណា ច វត នោ ចាទា　　ពាឡ្ហំ តរតិ ព្រាហ្មណោ
ឥតិ តត្ថ វិលបិំសុ　　កុមារា មាតុគិទ្ធិនោតិ ។

ឱអ្នកបងអើយ បាតជើងយើងទាំងពីរ សឹងពុរពងរងឈាម រអារអាមអស់ហើយ ឯណាផ្លូវឆ្ងាយមិតរាយទុគ៌ម ព្រាហ្មណ៍រឹងខំស្រូតរូតវាយបណ្ដើរជាខ្លាំង ទាំងព្រះអាទិត្យបិតនៅនាឋានទាប ទៀបនឹងអស្ដង្គត កំបាំងបាត់ពីមាត់ព្រៃហើយ វេលាថ្ងារនេះ យើងតែងបានយល់សម្ដេចព្រះជននី តែឯណាឡើយយើងនឹងបានយល់ព្រះភក្ត្រទៀត ។ អ្នកបងអើយ បើដូច្នេះ មកយើងនឹងលើកកម្បង់អញ្ជលីប្រណម្យស្រដីទៅនឹងអស់ទេវតា នៅនាស្រះស្រង់កំពង់ចុងឈើលើព្រៃភ្នំលតាវល្លិ សូមឱ្យអ្នកធ្យានទៅទូលសម្ដេចព្រះជននីនៃយើងថា ព្រាហ្មណ៍នេះវានាំយើង ពីអាស្រមដើរបង្ខំមកដល់ទ្វារព្រៃហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

យើងទាំងពីរ ឥតមានរោគាព្យាធិអ្វីបៀតបៀនឡើយ កុំឱ្យព្រះជននីអ្នកអាឡោះអាល័យបារម្ភមកដល់យើងទាំងពីរថ្វី ទើបថៅជាលីខំលើកព្រះហស្តទាំងពីរ ទាំងចំណងនោះឡើង បង្គំប្រណម្យសំបូងសង្រូងនូវអស់ទេវតា នៅនាដងព្រៃភ្នំនោះថា ភោន្តោ ទេវសង្ឃាយោបពិត្រពពួកទេវតាដ៏ចំរើនអើយ បណ្តាដែលគង់នៅក្នុងកំឡុងខ្ពង់ភ្នំដង្គុំព្រៃក្តី ស្តេចគង់កំឡុងព្រះឆ្នាំចាំរក្សានូវឈើទាំងឡាយក្តី ស្តេចគង់កំឡុងចុងស្មៅទាំងឡាយក្តី ស្តេចគង់ក្នុងកំឡុងស្រះថ្លា ដ៏មានបទុមាផ្កាឈូកក្តី បពិត្រអើយ សូមទានអ្នកករុណាមេត្តាលីលាទៅទូលសម្តេចព្រះវររាជជននីនៃយើងទាំងពីរថា ប្រសិនបើអ្នកមកតាមយើងខ្ញុំ កុំបង្អង់ឱ្យយូរឡើយ សូមឱ្យស្តេចអញ្ជើញមកឆាប់ ៗ ក្រែងអ្នកពុំស្គាល់ផ្លូវត្រង់តម្រង់ពីព្រះបរមសាលាមក គ្រាន់តែចុះជើងអ្នកមួយដើរទេ ។ បពិត្រទេវតាទាំងឡាយ សូមអញ្ជើញឱ្យអ្នកមកតាមផ្លូវនេះឯងក្រែងអ្នកបានមកយល់យើងខ្ញុំនេះឆាប់ហោង ។

ហៃភិក្ខុផងទាំងឡាយអើយ រីព្រះរាជកុមារទាំងពីរ ទ្រង់ព្រះកន្សែងយោបំ ទូលសូមអង្វរអស់ទេវតា នៅនាទ្វារភ្នំគិរីវង្កត ហេតុត្បិត

Websites: WatKhemaraRatanaram.org or WatKhmers.org

មានចិត្តស្រឡាញ់ អាឡោះអាល័យព្រះវរមាតាបិតា មុខគួរឱ្យអាសូរករុណាក្រៃពេកហោង ។

កុមារបព្វំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្ដែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក កណ្ឌកុមារបព្វ ដ៏ប្រដាប់នីទៅនូវព្រះគាថា ១០១ ព្រះគាថា ក៏ចប់បរិបូណ៌សមគួរដោយនូវវេលានេះឯងហោង ៕ ៚

(ចប់កណ្ឌកុមារបព្វ ទី ៨ តែប៉ុណ្ណោះ)

Websites: WatKhemaraRatanaram.org or WatKhmers.org

វាយខំព្យូទ័រសាឡើងវិញ

ដោយ

**ភិក្ខុ កិច្ចភិរតោ ឡាយ រិន**

និង

ត្រួតពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ

ដោយ

**លោកគ្រូ ធម្មនាថ ផនប្រសិទ្ធិ៍**

ដើម្បីផ្សព្វផ្សាយ ជូនជាធម្មទាន តាមវិបសាយ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង




Websites: WatKhemaraRatanaram.org or WatKhmers.org